ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ
វិទ្យាល័យសម្តេចអគ្គ. ហ៊ុន សែន សំពេង

**អបអរសាទរទិវាជាតិអំណានលើកទី៦**
**អត្ថបទសុំចូលរួមប្រឡងប្រណាំងតាក់តែងសិក្សាកថា**
**ក្រោមប្រធានបទ**

# តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ

**ដោយស្មេរ ឡុង ឆវឡ្យ**
ទូរសព្ទលេខ ០៧៧ ៨៤០ ៧១១
ប្រព័ន្ធតេឡេក្រាម ០៧៧ ៨៤០ ៧១១

**១១ មីនា ២០២១**

# មាតិកា

សេចក្ដីផ្ដើម ........................................................................................................១
១- ប្រភពរឿងរាមកេរ្តិ៍ .......................................................................................២
២- ទម្រង់រឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ ......................................................................២
៣- តួអង្គក្នុងរឿងរាមកេរ្តិ៍ ....................................................................................៣
៣.១- តួអង្គទេព ...................................................................................................៤
៣.២- តួអង្គអសុរៈ ................................................................................................៥
៣.៣- តួអង្គមុនីឥសី ព្រាហ្មណ៍ ....................................................................................៦
៣.៤- តួអង្គមនុស្ស ................................................................................................៧
៣.៥- តួអង្គសត្វ ...................................................................................................៧
៣.៦- តួអង្គរុក្ខជាតិ ................................................................................................៩
៤- តម្លៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ .........................................................................១០
៤.១- តម្លៃផ្នែកអត្ថន័យ ..........................................................................................១០
៤.១.១- តម្លៃក្នុងវិស័យប្រពៃណី ជំនឿ ទំនៀមទម្លាប់ ..........................................................១០
៤.១.១.១- វិស័យប្រពៃណី .............................................................................................១០
៤.១.១.២- វិស័យជំនឿ ទំនៀមទម្លាប់ ..................................................................................១១
៤.១.២- តម្លៃក្នុងវិស័យសិល្បៈ ......................................................................................១២
៤.១.៣- តម្លៃក្នុងវិស័យកីឡា .......................................................................................១៣
៤.១.៤- តម្លៃក្នុងវិស័យដាក់ឈ្មោះ ..................................................................................១៤
៤.១.៥- តម្លៃក្នុងវិស័យនយោបាយ ..................................................................................១៤
៤.១.៦- តម្លៃក្នុងវិស័យយុត្តិធម៌ ....................................................................................១៥
៤.២- តម្លៃផ្នែកអត្ថរូប ............................................................................................១៦
៤.២.១- តម្លៃផ្នែកសោភ័ណ .........................................................................................១៦
៤.២.២- តម្លៃផ្នែកសិល្បវិធីតែងនិពន្ធ ...............................................................................១៨
៤.២.២.១- វិធីតែងនិពន្ធ ...............................................................................................១៨
៤.២.២.២- វិធីបង្ហាញតួអង្គ ..........................................................................................១៩
៤.៤.២.៣- រូបារម្មណ៍វិធី .............................................................................................២០
៤.៣- តម្លៃផ្នែកអត្ថរស ............................................................................................២០
៤.៣.១- អច្ឆរិយរស .....................................................................................................២០

៤.៣.២- វីររស……………………………………………………………………………………………..២០
៤.៣.៣- តថរស……………………………………………………………………………………………..២១
៤.៣.៤- ទស្សនីយរស……………………………………………………………………………………….២១
៤.៣.៥- កុសលរស………………………………………………………………………………………..….២១
ឯកសារពិគ្រោះ ……………………………………………………………………………………………២២

# សេចក្ដីផ្ដើម

ដូចយើងបានដឹងហើយថា រឿងរាមកេរ្ដិ៍ខ្មែរមានប្រភពមកពីរឿងរាមាយណៈរបស់ឥណ្ឌាជាបទនិពន្ធដោយឥសីវាល្មិកិ(valmiki) នៅសតវត្សទី៣មនគ.ស.។ តាមរយៈភស្តុតាងចម្លាក់ឬសិលាចារឹក គេសង្កេតឃើញថារឿងនេះបានហូរចូលមកក្នុងសង្គមខ្មែរតាំងពីសម័យមុនអង្គរមកម្ល៉េះ។ សូមបញ្ជាក់ថានៅក្នុងស្រុកខ្មែរ រឿងរាមកេរ្ដិ៍មិនមែនមានត្រឹមតែបទនិពន្ធអក្សរសិល្ប៍ប៉ុណ្ណោះទេ ដ្បិតយើងឃើញមានរឿងរាមកេរ្ដិ៍ក្នុងទម្រង់សិល្បៈចម្លាក់ សិល្បៈគំនូរ អត្ថបទសំណេរ និងការពោលដោយមាត់ ជាដើម។ ម្យ៉ាងវិញទៀត រឿងរាមកេរ្ដិ៍ក្នុងសង្គមខ្មែរ មានទម្រង់បែបផែនទីទៃពីគ្នាខ្លះលើឈ្មោះតួអង្គឬសាច់ខ្លឹមសារទៅតាមទេសកាល តាមអ្នកពោលសម្ដែង ឬអ្នករៀបរៀង។

រាមកេរ្ដិ៍ មានន័យថា សេចក្ដីសរសើរ សេចក្ដីល្បីល្បាញនៃកេរ្ដិ៍ឈ្មោះរបស់តួអង្គព្រះរាមដែលជាអវតារទី៧របស់ព្រះវិស្ណុ។ រឿងនេះ ជាអក្សរសិល្ប៍ព្រាហ្មណ៍និយមដែលបានទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍ឬព្រហ្មញ្ញសាសនា ដែលមួយផ្នែក(ខ្សែទី១ដល់ខ្សែទី១០)និយាយពីការលើកសរសើរអាទិទេព ការប្រទ្បងប្រណាំងឫទ្ធិអំណាចគ្នា ព្រមទាំងចម្បាំងរាំងជល់ពោរពេញដោយអច្ឆរិយភាព និងមួយផ្នែកទៀត(ខ្សែទី៧៥ដល់ខ្សែទី៨០) និយាយពីជីវិតរស់នៅរបស់ព្រះរាមនិងគ្រួសារ។ យើងអាចនិយាយបានថា រឿងរាមកេរ្ដិ៍គឺជារឿងដែលបានលើកយកចំណោទបញ្ហាចម្បាំងមួយដ៏ធំរវាងតួអង្គអាទិទេពជាមួយតួអង្គអសុរៈដែលជាសភាវៈអាក្រក់ ហើយលទ្ធផលជ័យជម្នះបានមកខាងអាទិទេពតំណាងសភាវៈល្អ។

អស់រយៈកាលជាច្រើនរយឆ្នាំ រឿងនេះបានចូលជ្រួតជ្រាបស្ទើរគ្រប់សរសៃវប្បធម៌ខ្មែរ តួយ៉ាងក្នុងវិស័យប្រពៃណី ជំនឿ ទំនៀមទម្លាប់ វិស័យសិល្បៈ វិស័យកីឡា វិស័យដាក់ឈ្មោះ វិស័យនយោបាយ និងវិស័យយុត្តិធម៌ ជាដើម ព្រមទាំងដក់ជាប់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរផង។ មិនតែប៉ុណ្ណោះ រឿងរាមកេរ្ដិ៍ត្រូវបានគេបញ្ចូលក្នុងកម្មវិធីសិក្សាសម្រាប់សិស្សនិស្សិត តាំងពីថ្នាក់មធ្យមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។

ចំពោះការសិក្សាត្រួសៗនៅខាងក្រោមនេះ ស្មេរបានជ្រើសរើសយករឿងរាមកេរ្ដិ៍ដែលបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គឺជាច្បាប់របស់អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្សនិងជាច្បាប់របស់សាលាបារាំងចុងបូព៌ា។

## ១- ប្រភពរឿងរាមកេរ្តិ៍

កន្លងមក យើងឃើញមានអត្ថបទសិក្សាស្រាវជ្រាវនិងស្នាដៃជាច្រើនដែលនិយាយពីរឿងរាមកេរ្តិ៍ សុទ្ធតែបានបញ្ជាក់ស្របគ្នាថា រឿងរាមកេរ្តិ៍ខ្មែរមានប្រភពកំណើតចេញមកពីរឿងរាមាយណៈរបស់ឥណ្ឌា។ ម្យ៉ាងទៀត រឿងរាមាយណៈឥណ្ឌាមិនត្រឹមតែសាយភាយឥទ្ធិពលរបស់ខ្លួនចូលមកស្រុកខ្មែរតែមួយប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងតំបន់អាស៊ីអាគ្នេយ៍តួយ៉ាងដូចជាស្រុកសៀម(រ៉ាមាកៀន) ស្រុកលាវ(ផាលក្សណ៍ ផាឡាម) ឬនៅឥណ្ឌូណេស៊ី (Kakawin Rāmâna)ជាដើម ក៏រងឥទ្ធិពលរឿងរាមាយណៈនៅក្នុងវិស័យស្នាដៃអក្សរសិល្ប៍របស់ខ្លួនដែរ។

## ២- ទម្រង់រឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ

នៅក្នុងស្រុកខ្មែរ ដោយសំអាងលើភស្តុតាងចម្លាក់និងសិលាចារឹកនៅតាមប្រាសាទបុរាណ អ្នកសិក្សាស្រាវជ្រាវពិនិត្យឃើញថា រឿងរាមកេរ្តិ៍ចូលមកក្នុងសង្គមខ្មែរតាំងពីសម័យមុនអង្គរ។ បណ្ឌិត មីសែល ត្រាណេ[1] បានអះអាងថារឿងរាមកេរ្តិ៍កើតឡើងតាំងពីពាក់កណ្តាលសតវត្សទី៦នៃគ.ស. តាមរយៈភស្តុតាងរូបចម្លាក់ព្រះរាម ព្រះលក្ស្មណ៍ រាមបរមសូរ និងពលរាមនៅក្នុងរចនាបថភ្នំដា។

លុះមកដល់សម័យអង្គរ យើងកាន់តែឃើញចម្លាក់ច្រើនស្មុកស្មាញឆ្លាក់ពីដំណើររឿងរាមកេរ្តិ៍ តួយ៉ាងដូចជាចម្លាក់ប្រាសាទបន្ទាយស្រី ចម្លាក់នៅប្រាសាទអង្គរវត្តជាដើម។

នៅក្នុងសម័យកណ្តាល រឿងរាមកេរ្តិ៍បានចាប់កំណើតឡើងនៅក្នុងទម្រង់អត្ថបទកំណាព្យចារលើសាស្ត្រាស្លឹករឹត ប៉ុន្តែបានចម្លងបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលមានអ្នកសិក្សាស្រាវជ្រាវជាតិខ្មែរមួយចំនួនយល់ឃើញដូចខាងក្រោម៖

លោក **ញ៉ុក ថែម** បានលើកឡើងថា៖

- ខ្សែទី១ដល់ខ្សែទី១០ ប្រហែលរៀបរៀងឡើងនៅស.វ.ទី១៧-១៨ រវាងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី៤មកដល់ព្រះអង្គអេង ហើយនិពន្ធដោយអ្នកនិពន្ធតែម្នាក់(សាច់រឿងហាក់ដូចជាចប់មួយអន្លើទៅហើយ)
- ខ្សែទី៧៥ដល់ខ្សែទី៨០ ប្រហែលជាតែងក្នុងរជ្ជកាលព្រះអង្គអេងមកដល់ព្រះអង្គឌួង តែងដោយអ្នកនិពន្ធម្នាក់ទៀត។

អ្នកស្រី **ពៅ សាវរស** បានសិក្សានិងចែករឿងរាមកេរ្តិ៍ខ្មែរ(សៀវភៅដែលបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាពីរផ្នែកគឺ៖

- ផ្នែកទី១ ភាគទី១ដល់ភាគទី១០ មានទាំងអស់៥០៣៤វគ្គកំណាព្យ តែងឡើងរវាងសតវត្សទី១៦-១៧
- ផ្នែកទី២ ភាគទី៧៥ដល់ភាគទី៨០ មានទាំងអស់១៧៧៤វគ្គកំណាព្យ តែងឡើងរវាងពាក់កណ្តាលសតវត្សទី១៨។

សូមបញ្ជាក់ដែរថា ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពរឿងរាមកេរ្តិ៍ចំនួន៤លើកមកហើយ ដោយប្រើក្រដាស

[1] មីសែល ត្រាណេ, ការសិក្សារឿងរាមកេរ្តិ៍។

សៀវភៅខ្នាតតូច គឺបោះពុម្ពលើកទី១ ឆ្នាំ១៩៣៧, បោះពុម្ពលើកទី២ ឆ្នាំ១៩៥៩, បោះពុម្ពលើកទី៣ ឆ្នាំ១៩៦១ និងបោះពុម្ពលើកទី៤ ឆ្នាំ១៩៩៥។ ដោយផ្អែកលើសៀវភៅបោះពុម្ពផ្សាយលើកទី៤ ស្មេរពិនិត្យឃើញមាន៖

| **ផ្នែកទី១** | | |
|---|---|---|
| **ខ្សែ** | **ចំនួនល្បះ** | **ចំនួនទំព័រ** |
| ខ្សែទី១ | ៤៩៤ល្បះ | ៦៣ទំព័រ |
| ខ្សែទី២ | ៧១៧ល្បះ | ៨៧ទំព័រ |
| ខ្សែទី៣ | ៣៥៨ល្បះ | ៤៥ទំព័រ |
| ខ្សែទី៤ | ៥៣៥ល្បះ | ៧០ទំព័រ |
| ខ្សែទី៥ | ៤៣៦ល្បះ | ៥៣ទំព័រ |
| ខ្សែទី៦ | ៥២៨ល្បះ | ៦៣ទំព័រ |
| ខ្សែទី៧ | ៤៥៩ល្បះ | ៥៤ទំព័រ |
| ខ្សែទី៨ | ៥៩៣ល្បះ | ៧២ទំព័រ |
| ខ្សែទី៩ | ៤២១ល្បះ | ៥២ទំព័រ |
| ខ្សែទី១០ | ៣៨៣ល្បះ | ៤៨ទំព័រ |
| **សរុប** | **៤៩២៤ល្បះ** | |

| **ផ្នែកទី២** | | |
|---|---|---|
| **ខ្សែ** | **ចំនួនល្បះ** | **ចំនួនទំព័រ** |
| ខ្សែទី៧៥ | ៣១៨ល្បះ | ៦២ទំព័រ |
| ខ្សែទី៧៦ | ២៩៧ល្បះ | ៥៧ទំព័រ |
| ខ្សែទី៧៧ | ៣១៨ល្បះ | ៦២ទំព័រ |
| ខ្សែទី៧៨ | ២៩៩ល្បះ | ៥៦ទំព័រ |
| ខ្សែទី៧៩ | ២៩៦ល្បះ | ៥៦ទំព័រ |
| ខ្សែទី៨០ | ២៤១ល្បះ | ៤៨ទំព័រ |
| **សរុប** | **១៧៦៩ល្បះ** | |

ចំណែកសម័យទំនើប វត្តមានរឿងរាមកេរ្តិ៍បានបន្តលេចឡើងក្នុងទម្រង់សិល្បៈគំនូរឬចម្លាក់នៅវត្តអារាម ឬសិល្បៈល្ខោនពោលដោយសម្តី ដូចជា៖

- *គំនូររឿងរាមកេរ្តិ៍នៅវិហារព្រះកែវមរកត* ជាស្នាដៃរបស់សម្តេច វាំង ជួន តែងឡើងនៅឆ្នាំ១៩០៣នៃគ.ស.។
- *រឿងរាមកេរ្តិ៍ ពោលដោយតាគ្រុឌ* ថតខ្សែអាត់សំឡេងដោយ អាឡាំង ដានីញ៉ែល នៅឆ្នាំ១៩៦៧-១៩៦៨ នៃគ.ស.។
- *រឿងរាមកេរ្តិ៍ និទានដោយតាចក់* ចម្លងខ្សែអាត់សំឡេងនិងបោះពុម្ពផ្សាយជាសៀវភៅដោយលោក ហ្វ្រង់ស្វ័រ ប៊ីហ្សូត៍ នៅឆ្នាំ១៩៧៣នៃគ.ស.។
- *រឿងរាមកេរ្តិ៍ ពោលដោយតាសយ* ថតជាសំឡេងនិងរៀបបោះពុម្ពផ្សាយជាអត្ថបទសំណេរដោយលោក ពិ ប៊ុន្នីន នៅឆ្នាំ២០០០នៃគ.ស.។

## ៣- តួអង្គក្នុងរឿងរាមកេរ្តិ៍

ដូចយើងបានដឹងថា រឿងរាមកេរ្តិ៍គឺជាកម្រងវីរកថាដ៏វែង ដែលមួយផ្នែក(ខ្សែទី១-១០)រៀបរាប់ពីសង្គ្រាមរវាងតួអង្គអវតារអាទិទេពជាមួយនឹងអសុរៈ និងមួយផ្នែកទៀត(ខ្សែទី៧៥-៨០)បកស្រាយពីដំណើរជីវិតមនុស្សនិយមនៃតួអង្គព្រះរាមនិងញាតិវង្ស។ ដើម្បីបង្កើតដំណើររឿងឱ្យកាន់តែអស្ចារ្យ អ្នកនិពន្ធឬអ្នករៀបរៀងរឿងរាម

កេរ្តិ៍បានលើកបង្ហាញតួអង្គចម្រុះបែប រស់នៅទីឋានទីទៃពីគ្នា និងមានលក្ខណៈសម្បត្តិដោយឡែកពីគ្នាមកលាត ត្រដាង។ ឆ្លងតាមការអាននិងសិក្សារឿងរាមកេរ្តិ៍ ស្មេរសូមចែកតួអង្គជា៦ចំពូកផ្សេងគ្នា ដូចជាតួអង្គទេព តួអង្គ អសុរៈ តួអង្គឥសី តួអង្គមនុស្ស តួអង្គសត្វ និងតួអង្គរុក្ខជាតិ។

### ៣.១- តួអង្គទេព

នៅក្នុងប្រព័ន្ធជំនឿសាសនាព្រាហ្មណ៍ មានទេពច្រើនរាប់រយរាប់ពាន់អង្គដែលមាននាមផ្សេងៗគ្នា ឬទេព តែមួយតែមាននាមច្រើន តួយ៉ាងព្រះវិស្ណុមាននាមជាព្រះនារាយណ៍ ព្រះហរិ ព្រះភគវន្ត ព្រះអនន្ត ជាដើម។ នៅ ក្នុងចំណោមទេពទាំងនោះ មានទេពបីអង្គដែលគេចាត់ទុកជាធំកំពូលគេគឺ ព្រះព្រហ្ម ព្រះសិវៈ និងព្រះវិស្ណុ។ សម័យហិណ្ឌូនិយម ព្រះវិស្ណុត្រូវបានគេចាត់ទុកជាទេពដែលសំខាន់លើសលែងព្រះព្រហ្មនិងព្រះសិវៈ។ នៅក្នុង រឿងរាមកេរ្តិ៍ យើងឃើញមានវត្តមានតួអង្គទេពជាច្រើន និងប្រើពាក្យបញ្ជាក់ទេពដល់ទៅចំនួន៦៧៨ដង នៃចំនួន ដងតួអង្គសរុប៤៦៦៥។ នៅខ្សែ១ដល់ខ្សែ១០ តួអង្គព្រះរាមត្រូវបានគេលើកគុណសម្បត្តិជាអង្គអវតារតំណាង ព្រះវិស្ណុនិងមាននាទីកម្ចាត់អសុរៈដែលជាសភាវៈអាក្រក់។

**តារាងវត្តមានតួអង្គទេពនិងចំនួនដង**

| ល.រ. | ឈ្មោះទេព | ចំនួនដង | ល.រ. | ឈ្មោះទេព | ចំនួនដង |
|---|---|---|---|---|---|
| ១ | ព្រះនារាយណ៍ | ២០៣ | ១៥ | ពិស្ណុការ/ព្រះពិស្ណុការ | ៤ |
| ២ | ទេព/ទេពកញ្ញា/ទេពអប្សរ | ១៥៥ | ១៦ | ព្រះពិរុណ | ៤ |
| ៣ | ឥសូរ/ព្រះឥសូរ | ៨១ | ១៧ | ព្រះពៃស្រពណ៍ | ៣ |
| ៤ | សូរ្យ/សុរិយា/អាទិត្យ | ៤៦ | ១៨ | កោសី | ២ |
| ៥ | ព្រះឥន្ទ្រ/ឥន្ទ្រា | ៣៦ | ១៩ | គន្ធព្វ | ២ |
| ៦ | ចន្ទ្រ/ចន្ទ្រា | ៣០ | ២០ | ព្រះអគ្គី/ព្រះភ្លើង | ២ |
| ៧ | ព្រហ្ម/ព្រះព្រហ្ម | ២៤ | ២១ | ព្រះកាល | ២ |
| ៨ | ពាយ/ព្រះពាយ | ២៤ | ២២ | ព្រហស្បតិ៍ | ២ |
| ៩ | ព្រះហរិ | ១៦ | ២៣ | ព្រះសៅរ | ១ |
| ១០ | ព្រះសមុទ្រ | ១២ | ២៤ | ព្រះម្រឹត្យូវ | ១ |
| ១១ | ព្រះធរណី/គង្ហីង | ៩ | ២៥ | ព្រះនេហ្វ | ១ |
| ១២ | ពិស្ណុ/ព្រះពិស្ណុ | ៨ | ២៦ | ព្រះកេតុ | ១ |
| ១៣ | ព្រះសុក្រ | ៤ | ២៧ | ព្រះគង្គា | ១ |
| ១៤ | ព្រះយម | ៤ | | | |

## ៣.២- តួអង្គអសុរៈ

មិនថារឿងរាមាយណៈ រឿងរាមកេរ្តិ៍ ឬទេវកថាផ្សេងៗ អសុរៈឬយក្សត្រូវបានគេចាត់ទុកថាជាសភាវៈអាក្រក់ ដែលតែងប្រព្រឹត្តិទង្វើយាយី បៀតបៀនតួអង្គដទៃទាំងនៅឋានសួគ៌ឬឋានកណ្តាល។ អសុរៈឬយក្សអង្គខ្លះមានឫទ្ធិអំណាចធម្មតា(ចេះកាឡាខ្លួន ចេះហោះហើរ) ឯអង្គអសុរៈខ្លះទៀតមានឫទ្ធិអំណាចខ្លាំងក្រាស់ក្រៃ ដែលសូម្បីទេពនៅឋានសួគ៌ក៏កោតអំណាចចេស្តាដែរ។ ដូចអ្នកធ្លាប់អានរឿងរាមកេរ្តិ៍ដឹងហើយថា អសុរៈដែលមានឫទ្ធិអំណាចកំពូលគេគឺ ក្រុងរាពណ៍ឬទសមុខ ដែលជាស្តេចយក្សសោយរាជ្យនៅនគរលង្កា មានយក្សបរិវារសេនាជំនិត និងមានបុត្រចំណានៗជាច្រើនអង្គ។ ប្រសិនបើពិនិត្យដំណើររឿងរាមកេរ្តិ៍ដែលបោះផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ យើងឃើញវត្តមានតួអង្គអសុរៈឬយក្សដល់ទៅ១០៦៩ដង នៃចំនួនដងតួអង្គសរុប៤៦៦៥។ វត្តមាននេះលេចឡើងច្រើនជាងគេចាប់ពីខ្សែទី១ដល់ខ្សែ១០ ដែលបង្ហាញពីការបៀតបៀនរបស់អសុរៈលើតួអង្គទេពនិងយុទ្ធសង្គ្រាមដ៏វែងអន្លាយជាមួយតួអង្គទេព។

**តារាងវត្តមានតួអង្គអសុរៈនិងចំនួនដង**

| ល.រ. | ឈ្មោះតួអង្គ | ចំនួនដង | ល.រ. | ឈ្មោះតួអង្គ | ចំនួនដង |
|---|---|---|---|---|---|
| ១ | រាពណ៍ | ២៤១ | ២១ | ត្រីមុខ | ៨ |
| ២ | យក្ស/យក្សា | ១៨១ | ២២ | ប្រហោត | ៨ |
| ៣ | អសុរ/អសូរា | ១៤៩ | ២៣ | ត្រីសិរ | ៧ |
| ៤ | ពិភេក | ៨៥ | ២៤ | មហារីក | ៧ |
| ៥ | ឥន្ទ្រជិត | ៦៨ | ២៥ | មុខរក្ខ័ស | ៧ |
| ៦ | កុម្ភកាណ៍ | ៣៩ | ២៦ | សហស្សកុមារ | ៦ |
| ៧ | ខរ/ក្រុងខរ | ៣០ | ២៧ | មហាក្បាល | ៦ |
| ៨ | អតិកាយ | ២៣ | ២៨ | ស័តពលី | ៦ |
| ៩ | សូរបនខា | ២១ | ២៩ | រាហូ | ៥ |
| ១០ | រាមបរមសូរ | ១៩ | ៣០ | កាកនាសូរ | ៤ |
| ១១ | មណ្ឌោគិរី | ១៨ | ៣១ | នរាត័ក | ៤ |
| ១២ | ទូសណ៍ | ១៧ | ៣២ | រក្ខ័ស | ៥ |
| ១៣ | រក្ខសេន | ១៦ | ៣៣ | អាគុលយក្ខិនី | ៤ |
| ១៤ | មាលមាទ | ១៣ | ៣៤ | បរទុស្ត | ៣ |
| ១៥ | ភក្ខនេស | ១២ | ៣៥ | វិកតាសី | ៣ |

| | | | | | |
|---|---|---|---|---|---|
| ១៦ | កុម្ភន្ធ | ១១ | ៣៦ | មូលផល័ម | ២ |
| ១៧ | ទូរមុខ | ១០ | ៣៧ | កាមពាលី | ១ |
| ១៨ | មហោទរ | ១០ | ៣៨ | មហាកាយ | ១ |
| ១៩ | ពិរាធ | ៩ | ៣៩ | មហាបាស | ១ |
| ២០ | កុម្ភគទាធរ | ៨ | ៤០ | រុក្ខធន្ធ | ១ |

## ៣.៣- តួអង្គមុនីឥសី/ព្រាហ្មណ៍

មុនីឥសីនិងព្រាហ្មណ៍ គឺជាតួអង្គសំខាន់មួយមិនថានៅក្នុងរឿងបែបព្រាហ្មណ៍និយមឬពុទ្ធនិយមឡើយ។ វត្តមានឥសីឬវត្តមានព្រាហ្មណ៍នៅក្នុងដំណើររឿង តែងតែប្រកបដោយលក្ខណៈសម្បត្តិជាអ្នកមានចំណេះចេះដឹង មានសិល្បមន្តវិជ្ជាការ តាំងសមាធិ ធ្វើតបៈភាវនាធម៌នាអាស្រមក្នុងព្រៃ និងជាទីគោរពប្រណិប័តន៍ពីសំណាក់តួអង្គផងទាំងពួង ព្រមទាំងតែងជួយសង្គ្រោះយឹតយោងឬអន្តរាគមន៍តួអង្គដទៃ ជាពិសេសតួអង្គឯកដែលជួបទុក្ខលំបាកនៅក្នុងស្ថានភាពណាមួយ។ តួអង្គមុនីឥសីនិងព្រាហ្មណ៍នៅក្នុងរឿងរាមកេរ្តិ៍ យើងពិនិត្យឃើញមានវត្តមានដល់ទៅចំនួន១៥៦ដង នៃចំនួនដងតួអង្គសរុប៤៦៦៥។ នៅក្នុងនោះ តួអង្គមុនីឥសីឬព្រាហ្មណ៍ដែលលេចធ្លោនិងសំខាន់ជាងគេនៅក្នុងដំណើររឿងគឺ ឥសីពិស្វាមិត្រដែលត្រូវជាបិតាធម៌និងជាគ្រូបង្ហាត់បង្រៀនព្រះរាមនិងព្រះលក្ស្មណ៍ហូតចេះចប់គម្ពីរវេទ និងឥសីព្រះវជ្ជប្រិតដែលជួយមើលថែសីតានិងបុត្រក្រោយពេលដែលព្រះនាងត្រូវព្រះរាមបញ្ជាឱ្យព្រះលក្ស្មណ៍យកទៅសម្លាប់។

**តារាងវត្តមានតួអង្គមុនីឥសី/ព្រាហ្មណ៍និងចំនួនដង**

| ល.រ. | ឈ្មោះតួអង្គ | ចំនួនដង |
|---|---|---|
| ១ | ឥសី/ឫសី/ទេពឥសី//ឥសីទេវា/ព្រះឥសី/មហាឥសី/មុនី/មុនីឥសី | ១០៩ |
| ២ | តាបស/ព្រះតាបស | ១២ |
| ៣ | ព្រាហ្មណ៍ | ១២ |
| ៤ | មុនី/ព្រះមហាមុនី | ១១ |
| ៥ | ព្រះវជ្ជប្រិត | ៥ |
| ៦ | ពិស្វាមិត្រ | ៣ |
| ៧ | ព្រះភារទ្វារ/ឥសីពារទ្វារ | ២ |
| ៨ | មតង្គឥសី | ២ |

### ៣.៤- តួអង្គមនុស្ស

នៅក្នុងរឿងរាមកេរ្តិ៍ តួអង្គមនុស្សដែលបង្ហាញនាមជាក់លាក់ច្រើនមានចំពោះស្រទាប់រាជវង្ស មានជាអាទិ៍ រាជវង្សរបស់ព្រះបាទទសរថ ព្រះបាទជនក ឬកូខ័នដែលជាស្តេចព្រៃ ជាដើម។ តាមរយៈអំណានរឿងរាមកេរ្តិ៍ យើងស្រង់បានវត្តមានតួអង្គមនុស្សចំនួន៩៦០ដង នៃចំនួនដងតួអង្គសរុប៤៦៦៥។ ក្នុងនោះ វត្តមានតួអង្គព្រះរាមនិងព្រះលក្ស្មណ៍ យើងឃើញមាននៅគ្រប់ខ្សែនៃរឿង ពោលគឺតាំងពីដើមរឿងរហូតដល់ចប់រឿង។ ចំណែកព្រះញាតិដទៃទៀតរបស់ព្រះរាម(ក្រៅពីព្រះលក្ស្មណ៍) ច្រើនមានវត្តមាននៅខ្សែទី១ ខ្សែទី២ និងពីខ្សែទី៧៥ដល់ខ្សែទី៨០។

**តារាងវត្តមានតួអង្គមនុស្សនិងចំនួនដង**

| ល.រ. | ឈ្មោះតួអង្គ | ចំនួនដង | ល.រ. | ឈ្មោះតួអង្គ | ចំនួនដង |
|---|---|---|---|---|---|
| ១ | រាម/រាមា/ព្រះរាម/ព្រះរាមា | ២៧០ | ៨ | កៃកេសី(មហេសីទី២របស់ស្តេចទសរថ) | ៣៨ |
| ២ | លក្ស្មណ៍/លក្សា/ព្រះលក្ស្មណ៍ | ១៨៥ | ៩ | ជប្បលក្ស្មណ៍ | ២៩ |
| ៣ | សីតា(មហេសីព្រះរាម) | ១២០ | ១០ | ទសរថ/ព្រះទសរថ/ព្រះបាទទសរថ/ស្រីទសរថ | ២៧ |
| ៤ | ភិរុត/ព្រះភិរុត | ១១០ | ១១ | ព្រះជនក/ព្រះបាទជនក | ១៨ |
| ៥ | កូខ័ន(ស្តេចព្រៃ) | ៤៧ | ១២ | កោសកល្យាណ(អគ្គមហេសីស្តេចទសរថ) | ១៣ |
| ៦ | ព្រះសុត្រុត | ៤៦ | ១៣ | រុទ្ធរៈ | ៧ |
| ៧ | រាមលក្ស្មណ៍(បុត្រព្រះរាម) | ៤២ | ១៤ | សមុទ្រ(មហេសីទី៣របស់ស្តេចទសរថ) | ៤ |
| ១៥ | អនុជិត | ៤ | | | |

### ៣.៥- តួអង្គសត្វ

នៅក្នុងជំនឿសាសនាព្រាហ្មណ៍ សត្វខ្លះបានដើរតួជាជំនិះ ជាអវតារ ឬជាតួតំណាងរបស់ព្រះ របស់ទេវៈឬអាទិទេព។ ដូចយើងធ្លាប់ដឹងថា ទេពសំខាន់ៗក្នុងសាសនាព្រាហ្មណ៍សុទ្ធសឹងតែមានជំនិះផ្ទាល់ព្រះអង្គ ដូចយ៉ាងព្រះព្រហ្មមានហង្សជាជំនិះ ព្រះសិវៈមានគោនិន្ទជាជំនិះ ព្រះវិស្ណុមានគ្រុឌជាជំនិះ។ ជាតឹកតាងបញ្ជាក់បន្ថែម រឿងរាមកេរ្តិ៍ខ្សែ១ យើងឃើញវត្តមានទេពភ្ជាប់ជាមួយនឹងជំនិះព្រះអង្គ ដូចឃ្លាកំណាព្យ *"...ព្រះឥន្ទ្រស្តេចលើឰរាអមរនោគេន្ទ្រា ស្មើរុងរឿងគិតដ៏ថ្កើង។ ព្រះអគ្គីស្តេចលើមាសភ្លើង តេជោជ័យថ្កើង ឫទ្ធីមាសមោះហិមា។ ព្រះពាយផ្សាយផ្សព្វវេហាស៍ អស្សពាហន៍លេលា គឺពាយក៏បក់បីប្របារ។ ព្រះពិរុណព្រះអង្គបីឌទារ ស្តេចលើនាគនាថ៌ ពិពិធពិពណ៌ជលជី។ ព្រះចន្ទ្រកុមារស្តេចលីលាលើបក្សី សុពណ៌មយូរចេនា។ ព្រះព្រហ្មទ្រង់ព្រតសីលា ស្តេចលើហង្សា ធិរាជរឹងឫទ្ធិដ៏តបៈ។ ព្រះនេហ្សតិរាជតេជៈ គង់លើយក្សតបៈ កំឡាំងក៏ស្តេចយាត្រា។ ព្រះពៃស្រីពណ៌រាជដ៏មហា ធិបតិន្ទលេលា លើក្រាយពិមានដ៏មង្គល។ ព្រះឥសូរសិទ្ធិសក្តិ៍សួស្តីសល់ ត្រៃកពដ៏*

*មណ្ឌល សំណាក់នៃទេពឥន្ទ្រា។ ស្តេចលើឧសភរាជដ៏មហា អតិរេកមោះហិមា- នុភាពអំណាចព្រះធនូ...*"។ ពិនិត្យតាមដំណើររឿង វត្តមានតួអង្គសត្វយើងស្រង់បានចំនួន១៦៥២ដង នៃចំនួនដងតួអង្គសរុប៤៦៦៥។ ក្រៅពីសត្វដែលជាជំនិះរបស់ទេពឬទាក់ទងនឹងទេព អ្នកនិពន្ធឬអ្នករៀបរៀងក៏បានរំលេចវត្តមានតួអង្គសត្វចម្រុះបែបផ្សេងទៀត មានជាអាទិ៍សត្វស្លាប សត្វម្រឹគ សត្វល្អិត ឬមច្ឆា ជាដើម ដែលមួយចំនួនធំសុទ្ធសឹងជាសត្វមាននៅក្នុងស្រុកខ្មែរ និងមានឈ្មោះហៅដោយប្រើពាក្យខ្មែរក៏មានចំនួនច្រើន។

**តារាងវត្តមានតួអង្គសត្វនិងចំនួនដង**

| ល.រ. | ឈ្មោះតួអង្គ | ចំនួនដង | ល.រ. | ឈ្មោះតួអង្គ | ចំនួនដង | ល.រ. | ឈ្មោះតួអង្គ | ចំនួនដង |
|---|---|---|---|---|---|---|---|---|
| ១ | ពានរ/ពានរា/ពានរិន្ទ្រ/ស្វា | ៣០៨ | ៣១ | ភូមរ/ភូមរា/ភូមរី | ៥ | ៦១ | សារិកា | ២ |
| ២ | ហនុមាន(ស្វា) | ២៥៥ | ៣២ | ប្រើស | ៤ | ៦២ | សេក | ២ |
| ៣ | ពលី/ពាលី/ក្រុងពាលី(ស្វា) | ១២៧ | ៣៣ | មករ | ៤ | ៦៣ | ស្វាន | ២ |
| ៤ | សុគ្រីព(ស្វា) | ១០៣ | ៣៤ | មាន់ទឹក/មាន់ព្រៃ | ៤ | ៦៤ | សំពោច | ២ |
| ៥ | អង្គទ(ស្វា) | ១០១ | ៣៥ | រមាំង | ៤ | ៦៥ | ហូពូ(ហ៊ូពូ) | ២ |
| ៦ | នាគ/នាគា/នាគី | ៨៦ | ៣៦ | ហង្ស | ៤ | ៦៦ | ឱឡ | ២ |
| ៧ | ពាជី/សេះ/អស្សតរ/អស្សពាហ៍ | ៧៨ | ៣៧ | ក្រសា | ៤ | ៦៧ | អាអូត | ២ |
| ៨ | ខុននីល(ស្វា) | ៧២ | ៣៨ | កាក/ក្អែក | ៣ | ៦៨ | ទន្សង | ១ |
| ៩ | ក្របី/មហិង្ស/មហិង្សា | ៦៤ | ៣៩ | ក្រួច | ៣ | ៦៩ | កន្លង់ | ១ |
| ១០ | គជ/គជសារ/គជសីហ៍ | ៥៣ | ៤០ | ខុននន្ទ(ស្វា) | ៣ | ៧០ | ក្ងាន | ១ |
| ១១ | ទូភី(ក្របី) | ៣៩ | ៤១ | ក្រៀល | ៣ | ៧១ | ក្ង | ១ |
| ១២ | តោ/សិង្ហ/សីហ | ៣២ | ៤២ | ខ្លែងខ្មោច/ខ្លែងស្រាក | ៣ | ៧២ | កំប្រុក | ១ |
| ១៣ | មហាជម្ពូ(ស្វា) | ២៥ | ៤៣ | ឆ្កែ | ៣ | ៧៣ | ខោរ(ស្វា) | ១ |
| ១៤ | គោ/គោមហិង្សា/ឧសភ | ២៥ | ៤៤ | ទោច | ៣ | ៧៤ | ឃ្មុំ | ១ |
| ១៥ | គ្រុឌ/គ្រុឌា | ១៩ | ៤៥ | ទៀវ | ៣ | ៧៥ | ថ្លាន់ | ១ |
| ១៦ | ខុននល(ស្វា) | ១៩ | ៤៦ | លៀងភា | ៣ | ៧៦ | ទទា | ១ |
| ១៧ | ខ្លា/ព្យគ្ឃ | ១៤ | ៤៧ | ក្អែប | ២ | ៧៧ | ទីទុយ | ១ |
| ១៨ | ម្រឹគ/ម្រឹគា/ម្រឹគី | ១៤ | ៤៨ | ខុនជីព(ស្វា) | ២ | ៧៨ | ប៉ម៉ង់(ប្រមង់) | ១ |
| ១៩ | រាជសីហ៍ | ១៣ | ៤៩ | ខ្សងហៀន | ២ | ៧៩ | ប៉ោលតោក | ១ |
| ២០ | ជតាយុ(គ្រុឌ) | ១២ | ៥០ | ខ្ជួយ | ២ | ៨០ | ប្រវឹក | ១ |
| ២១ | ជម្ពូ/ជម្ពូពាន(ស្វា) | ១០ | ៥១ | ចចក | ២ | ៨១ | ពម៉ា(ប្រមា) | ១ |
| ២២ | រមាស | ១០ | ៥២ | ត្មាត | ២ | ៨២ | ព្រាប | ១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៣ | កុក | ៨ | ៥៣ | ទន្សាយ | ២ | ៨៣ | មមាច | ១ |
| ២៤ | ក្ងោក/មយូរ/មយូរី | ៧ | ៥៤ | ទន្សោង | ២ | ៨៤ | រុយ | ១ |
| ២៥ | ត្រី/មច្ឆា | ៧ | ៥៥ | ទុង | ២ | ៨៥ | រៃ(រៃកណ្ដឹង) | ១ |
| ២៦ | ពស់ | ៧ | ៥៦ | ទោម | ២ | ៨៦ | លា | ១ |
| ២៧ | ពិពិត្រ | ៧ | ៥៧ | ពពូល | ២ | ៨៧ | សន្តគិរី(ក្របី) | ១ |
| ២៨ | ភូជង្គ | ៦ | ៥៨ | មមង់ | ២ | ៨៨ | សុច | ១ |
| ២៩ | កេសរ(ស្វា) | ៥ | ៥៩ | មូស | ២ | ៨៩ | ឱដ្ឋ(ឧដ្ឋ) | ១ |
| ៣០ | ទ្រាយ | ៥ | ៦០ | របោម | ២ | ៩០ | ឥន្ទ្រី | ១ |

**៣.៦- តួអង្គរុក្ខជាតិ**

មនុស្សរស់នៅតែងមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងរុក្ខជាតិឬធម្មជាតិជុំវិញខ្លួន។ ដ្បិតមនុស្សត្រូវការអាស្រ័យផលរុក្ខជាតិសម្រាប់បរិភោគឬទទួលទាន ប្រើជាឱសថព្យាបាលជំងឺ ជម្រក ប្រព័ន្ធជីវចម្រុះ បរិយាកាស ព្រមទាំងផ្តល់អុកស៊ីសែនសម្រាប់ដកដង្ហើម។ កម្ពុជាពីអតីតកាល ធ្លាប់ជាប្រទេសមួយដែលសម្បូរសម្បត្តិធម្មជាតិជាពិសេសព្រៃឈើ។ ស្នាដៃអក្សរសិល្ប៍ខ្មែរ ជាអាទិ៍អក្សរសិល្ប៍បុរាណតែងរំលេចនូវវត្តមានរុក្ខជាតិធម្មជាតិយ៉ាងសម្បូរបែបរបស់ខ្មែរ ដែលបង្កើតបានជាផ្ទាំងទស្សនីយភាពមួយដ៏ល្អជំរុញទៅលើកតម្លៃមួយផ្នែក(សោភ័ណ)នៃស្នាដៃអក្សរសិល្ប៍សិល្បៈ។ ងាកមករឿងរាមកេរ្តិ៍ បើទោះបីជាមានប្រភពមកពីរឿងរាមាយណៈឥណ្ឌាម្តេចក្តី ក៏ប៉ុន្តែអ្នកនិពន្ធឬអ្នករៀបរៀងខ្មែរយើងបានលាតត្រដាងពីរុក្ខជាតិពិតៗដែលមាននៅក្នុងស្រុកខ្មែរ ប្រកបដោយកំណាព្យចាប់ចុងចួនយ៉ាងពីរោះរណ្តំ។ ការបង្ហាញរុក្ខជាតិធម្មជាតិនេះទៀតសោត ច្រើនលេចឡើងនៅពេលតួអង្គទទួលរងទុក្ខខ្លោចផ្សារ កណ្តោចកណ្តែង ត្រាច់រង្គត់នៅក្នុងព្រៃ ឬម្តងម្កាលដោយចម្បាំង(រវាងក្រុមតំណាងអាទិទេពនិងក្រុមយក្ស)។ យ៉ាងណាមិញ តាមការពិនិត្យលើដំណើររឿង យើងស្រង់តួអង្គរុក្ខជាតិបានចំនួន១២១ដង នៃចំនួនដងតួអង្គសរុប៤៦៦៥។

**តារាងវត្តមានតួអង្គរុក្ខជាតិនិងចំនួនដង**

| ល.រ. | ឈ្មោះ រុក្ខជាតិ | ចំនួន ដង | ល.រ. | ឈ្មោះ រុក្ខជាតិ | ចំនួន ដង | ល.រ. | ឈ្មោះ រុក្ខជាតិ | ចំនួន ដង |
|---|---|---|---|---|---|---|---|---|
| ១ | ដើមតាល/ត្នោត/សប្តតាល | ១៥ | ២២ | គូលែន | ១ | ៤៣ | មាក់ប៉ែន | ១ |
| ២ | ឈូក/បទុម/បូទុម | ១២ | ២៣ | គ្រង់ | ១ | ៤៤ | មាក់ប្រេង | ១ |
| ៣ | ស្វាយ | ៩ | ២៤ | គ្រញូង | ១ | ៤៥ | រមៀត | ១ |
| ៤ | ដើមរាំង | ៧ | ២៥ | គ្រើល | ១ | ៤៦ | រំដួល | ១ |
| ៥ | ដូង | ៤ | ២៦ | ចន្ទន៍ | ១ | ៤៧ | លៀប | ១ |
| ៦ | ស្លា | ៤ | ២៧ | ចម្បី | ១ | ៤៨ | ល្មុត | ១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៧ | គុយ | ៣ | ២៨ | ច្បា | ១ | ៤៩ | លំពង់ | ១ |
| ៨ | បង្គោ | ៣ | ២៩ | ជន្លួស | ១ | ៥០ | លំពោះ | ១ |
| ៩ | មង្សុត | ៣ | ៣០ | ជ្រៃ | ១ | ៥១ | សូក្រំ | ១ |
| ១០ | ក្រសាំង | ២ | ៣១ | ជ្រៃ | ១ | ៥២ | សូរភី | ១ |
| ១១ | ក្រាយ | ២ | ៣២ | ដង្កូម | ១ | ៥៣ | សេដា | ១ |
| ១២ | ក្រូច | ២ | ៣៣ | ទន្លាប់ | ១ | ៥៤ | សេរមាន់(សិរមាន់) | ១ |
| ១៣ | ចម្ប៉ា | ២ | ៣៤ | ទូរេន | ១ | ៥៥ | ស្ដី | ១ |
| ១៤ | ភ្ញៀវ | ២ | ៣៥ | ទំពូង | ១ | ៥៦ | ស្ដៅ | ១ |
| ១៥ | មាក់ប្រាង | ២ | ៣៦ | ននោង | ១ | ៥៧ | ស្បូវ | ១ |
| ១៦ | ស្មី | ២ | ៣៧ | បក់ | ១ | ៥៨ | ស្មាច់ | ១ |
| ១៧ | ស្រគំ | ២ | ៣៨ | បុសនាគ | ១ | ៥៩ | ស្មៃ | ១ |
| ១៨ | ក្រកោះ | ១ | ៣៩ | ព្នៃល | ១ | ៦០ | ស្រឹង | ១ |
| ១៩ | ក្រស្នា | ១ | ៤០ | ញ្ញៅ | ១ | ៦១ | អញ្ចាន់ | ១ |
| ២០ | ក្រាស | ១ | ៤១ | ព្រីង | ១ | ៦២ | ឧត្បល | ១ |
| ២១ | កំភ្លឹង | ១ | ៤២ | ព្រូស | ១ | | | |

## ៤- តម្លៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ

### ៤.១- តម្លៃផ្នែកអត្ថន័យ

#### ៤.១.១- តម្លៃក្នុងវិស័យប្រពៃណី ជំនឿ និងទំនៀមទម្លាប់

មនុស្សតាមជាតិសាសន៍នីមួយៗតែងបង្កើតបានប្រពៃណី ជំនឿនិងទំនៀមទម្លាប់របស់ខ្លួនស្របទៅតាមផ្នត់គំនិត ចំណង់ចំណូលចិត្ត ស្ថានភាពភូមិសាស្ត្រ ធម្មជាតិ អាកាសធាតុ ឬរបត់នយោបាយសង្គមជាដើម។ ប្រពៃណី ជំនឿនិងទំនៀមទម្លាប់ទាំងនោះរមែងបានរីកចម្រើនឬឱនថយទៅវិញក៏អាស្រ័យដោយមនុស្សសាសន៍នោះឯងរួមគ្នាកសាង លើកតម្កើង ថែរក្សា និងអភិវឌ្ឍ។ ដូនតាខ្មែរតាំងពីបុរាណកាលបានបន្សល់ទុកប្រពៃណីជំនឿនិងទំនៀមទម្លាប់ច្រើនស្អេកស្កះ។ ប៉ុន្តែនៅក្នុងទីនេះ យើងសូមលើកបង្ហាញត្រួសៗនូវប្រពៃណី ជំនឿនិងទំនៀមទម្លាប់មួយចំនួនតាមរយៈរឿងរាមកេរ្តិ៍ ដែលយើងនៅតែឃើញមានប្រតិបត្តិក្នុងសង្គមខ្មែរសព្វថ្ងៃ។

##### ៤.១.១.១- វិស័យប្រពៃណី

ប្រពៃណីខ្មែរ មានច្រើនបែបច្រើនសណ្ឋានណាស់តាំងពីបរមបុរាណរហូតដល់បច្ចុប្បន្ន និងបានជ្រួតជ្រាបចូលគ្រប់ស្រទាប់មនុស្សក្នុងសង្គមខ្មែរ រាប់តាំងពីព្រះមហាក្សត្រ មន្ត្រី រាស្ត្រ ឬកសិករ។ ឆ្លុះបញ្ចាំងតាមរយៈរឿងរាមកេរ្តិ៍ យើងសង្កេតឃើញមានប្រពៃណីសំខាន់ៗមួយចំនួនដែលមានឥទ្ធិពលនិងប្រតិបត្តិក្នុងសង្គមខ្មែរដូចជា៖

- **ពិធីច្រត់ព្រះនង្គ័ល :** ច្រត់ព្រះនង្គ័ល ជាកិច្ចប្រពៃណីដែលមានជាប់ទាក់ទងនឹងសាសនាព្រាហ្មណ៍។ នៅ

ក្នុងរឿងរាមកេរ្តិ៍ខ្សែ១ យើងឃើញតួអង្គស្តេចជនកទ្រង់ប្រារព្ធពិធីនេះ សម្រាប់ជាប្រយោជន៍សុខក្សេមក្សាន្តជូនប្រជារាស្ត្រនគរព្រះអង្គ។ ចំពោះក្នុងសង្គមខ្មែរវិញ នៅខែពិសាខនៃឆ្នាំនីមួយៗ យើងឃើញព្រះមហាក្សត្រទ្រង់យាងជាព្រះរាជាធិបតីប្រារព្ធពិធីច្រត់ព្រះនង្គ័លដែរ។

○ **ប្រពៃណីស្នងរាជសម្បត្តិ** : ចំពោះរបបនយោបាយរាជានិយម បវេណីនៃការស្នងរាជសម្បត្តិ គឺត្រូវបានទៅលើបុត្រច្បងនៃអគ្គមហេសី។ បុត្របន្ទាប់មិនអាចរឹងទទឹង ប៉ះបោរ ប្រឆាំងចង់បានរាជសម្បត្តិឡើយ ដ្បិតខុសនឹងបវេណីនាំឱ្យរាស្ត្រទូទៅចំអកនិន្ទា ប៉ះពាល់ដល់ព្រះកិត្តិយស។ រឿងរាមកេរ្តិ៍បានបង្ហាញពីវិបត្តិរាជវង្សដោយសារតែបញ្ហារាជសម្បត្តិ។ ព្រះបាទទសរថបានជាជ្រុលសន្យាពាក្យសត្យនឹងនាងកៃកេសីថា ឱ្យព្រះភិរុតឡើងសោយរាជ្យបន្ទាប់ពីព្រះអង្គ។ ជាក់ស្តែងព្រះភិរុតជាអនុជរបស់ព្រះរាម តាមប្រពៃណីរាជសម្បត្តិមិនត្រូវបានលើព្រះភិរុតទេ។ ព្រះភិរុតផ្ទាល់ព្រះអង្គតាំងគោរពប្រពៃណីនេះមុតមាំ គោរពស្រឡាញ់ព្រះរាម និងមិនអាចឡើងសោយរាជសម្បត្តិមុនបងបានដែរ។

○ **ពិធីមង្គលការ** : មង្គលការ ជាកិច្ចប្រពៃណីមួយក្នុងន័យផ្សំផ្គុំកូនប្រុសស្រីឱ្យក្លាយជាប្រពន្ធប្តីនឹងគ្នា។ ជាទូទៅ ម្តាយឪពុកទាំងពីរខាងតែងរំពឹងចង់បានអនាគតកូនប្រសាដែលមានទាំងសមត្ថភាព ទាំងចំណេះដឹង សីលធម៌ល្អថ្លៃថ្នូរ ឬមានលក្ខខណ្ឌសមស្របក្នុងការផ្តល់សុភមង្គលជូនគ្រួសារថ្មីរបស់កូនៗ។ ងាកមកក្នុងរឿងរាមកេរ្តិ៍ យើងដឹងថាព្រះជនកបានជ្រើសរើសស្វាមីជូនបុត្រីដោយពិធីលើកធ្នូ មានន័យថាជាការរើសរកបុត្រសុនិសាដែលខ្លាំងមានសមត្ថភាព។ ម្យ៉ាងវិញទៀត ចំពោះកិច្ចមង្គលអាពាហ៍ពិពាហ៍ត្រូវមានការចូលរួមជាធំពីម្តាយឪពុកនិងប្រារព្ធធ្វើនៅខាងកូនស្រី។

### ៤.១.១.២- វិស័យជំនឿនិងទំនៀមទម្លាប់

០ **ជំនឿទាក់ទងនឹងសត្វកុក** : យើងច្រើនស្គាល់ កុក ថាជាបក្សីមួយប្រភេទ ចាប់ត្រីរស់ជាអាហារ។ ប៉ុន្តែនៅក្នុងផ្នែកជំនឿវិញ ចាស់ៗមួយចំនួនតែងកត់សម្គាល់ថាកុកជាសត្វចង្រៃឬនាំគ្រោះមិនល្អ ពិសេសនៅពេលវាហើរវិលងដំបូលផ្ទះឬទំលើដំបូលផ្ទះ។ រឿងរាមកេរ្តិ៍ខ្សែទី៤ ទំព័រ៣៥ បានបង្ហាញឱ្យយើងឃើញពីជំនឿទាក់ទងនឹងកុក។ ពេលស្វែងរកព្រះនាងសីតា ព្រះរាមនិងព្រះលក្សណ៍បានជួបនឹងកុក ពេលនោះព្រះលក្សណ៍បានថ្លែងចំៗថាកុកចង្រៃ។ ទាំងកុកខ្លួនឯងក៏បានបញ្ជាក់ថាខ្លួនចង្រៃដែរ ដូចមានឃ្លាកំណាព្យថា *"នាអង្គអញខ្ញុំសព្វថ្ងៃ អនេកបីចង្រៃ រាហូឧបទ្រុពណា។ ព្រះអង្គនឹងចាប់លង្កា នាថ្ងៃណាៗ ព្រះអង្គប្រមាណអញខ្ញុំ។ អញខ្ញុំហើរដោយបីជុំ បន្ទាយលង្កាធំ នោះសូន្យលង្កាអន្តរាយ"*។ លុះសង្គ្រាមកើតឡើងនៅក្រុងលង្កាវាងទ័ពខាងព្រះរាមនិងទ័ពក្រុងរាពណ៍ លទ្ធផលគឺក្រុងលង្កាទាំងមូលត្រូវវិនាសដូចកុកបញ្ជាក់មែន។

០ **ជំនឿខាងក្បួនទស្សន៍ទាយ** : ខ្មែរធ្លាប់និយមជឿទៅលើក្បួនទស្សន៍ទាយតាំងពីសម័យព្រេងនាយមកដល់បច្ចុប្បន្ន។ យើងឃើញមានក្បួនទស្សន៍ទាយថ្ងៃខែឆ្នាំ ទាយមើលគ្រោះ ទាយជោគជតារាសី ទាយកាត់សប្តិជាដើម។ ផ្អែកលើរឿងរាមកេរ្តិ៍ មានតួអង្គហោរាទស្សន៍ទាយចំណានៗដូចជា ពិភេក ប្រហេត និងជម្ពូពាន ដែលសុទ្ធ

សឹងទាយដំណើរហេតុភេទបានឲតធាប់ដូចសេចក្តីពិត។ នៅក្នុងចំណោមហោរាទាំងបីខាងលើនេះ យើងសង្កេតពិនិត្យឃើញឈ្មោះហោរាពិភេក មានឥទ្ធិពលណាស់នៅក្នុងប្រព័ន្ធជំនឿទស្សន៍ទាយក្នុងសង្គមខ្មែរ។ ឧទាហរណ៍ក្បួនទាយពិភេក សេះ៦ *"កាលព្រះលក្សណ៍អនុជា ចេញសាងចរិយាចិត្តស្មោះសរ មានយក្សមេម៉ាយរូបល្អ ចង់បានពុទ្ធោរួមពិសម័យ"* បង្ហាញពី

○ **ជំនឿមន្តគាថា** : តាមយើងធ្លាប់ដឹង មន្តគាថា គឺគេធ្វើសម្រាប់ជាគ្រឿងរក្សាការពារខ្លួនពីគ្រោះភ័យន្តរាយការពារកុំឱ្យខ្មោចព្រាយបិសាចយាយី ឬសម្រាប់ប្រសិទ្ធីសុខសួស្តីផ្សេងៗទៀត។ ទំនៀមពីដើមរៀងមក បុគ្គលចេះមន្តគាថាច្រើនជាព្រាហ្មណ៍ ឥសី បព្វជិតសង្ឃ ឬគ្រូហ្មទ្យ។ល។ ចំពោះរឿងរាមកេរ្តិ៍ យើងសុទ្ធតែបានឃើញថាតួអង្គជាច្រើនចេះមន្តអាគមគាថា អាចសូត្រសែកជបសិល្ប៍ទិព្វមន្ត សណ្តំអន្ទង ប្រកបដោយអច្ឆរិយភាពជាពន្លឹក។ រីឯក្នុងសង្គមមនុស្សជាក់ស្តែង យើងក៏ពិនិត្យឃើញមានកិច្ចប្រតិបត្តិមន្តគាថាតាំងពីដើមរៀងមកដែរ។ តួយ៉ាងដូចជាមន្តគាថាបទសរព្រះនារាយណ៍ទាំង៥ សម្តែងដូច្នេះថា *"ឥតិបិសោភគវា ខ្ញុំសូមរាជនា សរព្រះនារាយណ៍ឫទ្ធិវង់ ខ្ញុំសូមលើកកម្សង់ ផ្ទង់អារាជនា សរព្រះព្រហ្មាស។"*... សំដៅសេចក្តីថាសូមឱ្យបានកម្ចាត់នូវឧបទ្រព្យចង្រៃផងទាំងពួង សូមឱ្យបានឈ្នះមានពន្លឺចែងចាំង...។

○ **ទំនៀមកោរជុក** : យើងអាចនិយាយថា *កោរជុក* គឺជាកិច្ចទំនៀមមួយដែលរៀបចំឡើងក្នុងអត្ថន័យផ្តល់មង្គលជូនកូនប្រុសស្រីនៅមុនពេលពេញវ័យ។ ប្រភពនៃទំនៀមកោរជុកក្នុងសង្គមខ្មែរ មានតាំងពីពេលដែលខ្មែរកាន់សាសនាព្រាហ្មណ៍មកម្ល៉េះ។ នៅសម័យបុរាណរហូតដល់ដើមសតវត្សទី២០ ទំនៀមនេះទំនងនៅនិយមចំពោះគ្រប់ស្រទាប់មនុស្សក្នុងសង្គមខ្មែរទោះទាំងបុត្រមហាក្សត្រ កូនមន្ត្រី ឬកូនប្រជាពលរដ្ឋដែលមានធនធានស្តុកស្តម្ភ។ ឯកសារស្រាវជ្រាវមួយ(2)បានបង្ហាញថា *ក្នុងគំនូររឿងរាមកេរ្តិ៍នៅវិហារវត្តបូព៌ ក្រុងសៀមរាប មានឈុតមួយនិយាយពីពាលីយកអង្គទជាកូនទៅកោរសក់ ឯបុព្វជិតជាអ្នកធ្វើកិច្ចនោះជាតាឥសី ហាក់ដូចជាប្រពៃណីព្រាហ្មណ៍ដូច្នោះ*។ យ៉ាងណាមិញនៅសង្គមខ្មែរបច្ចុប្បន្ន យើងសង្កេតឃើញទំនៀមកោរជុកនៅធ្វើតិចតួចបំផុតតាមខេត្តខណ្ឌខ្លះប៉ុណ្ណោះ ដូចជាតំបន់អង្គរជាដើម។

**៤.១.២- តម្លៃក្នុងវិស័យសិល្បៈ**

រឿងរាមកេរ្តិ៍បានជ្រួតជ្រាបទៅក្នុងវិស័យសិល្បៈខ្មែរជាច្រើនទម្រង់ ដូចជាសិល្បៈល្ខោន សិល្បៈចម្លាក់-គំនូរ និងសិល្បៈអក្សរសិល្ប៍ ជាដើម។ ចំពោះសិល្បៈល្ខោនដែលយកសាច់រឿងរាមកេរ្តិ៍ទៅសម្តែង យើងសង្កេតឃើញមានក្នុងទម្រង់ល្ខោនខោល ល្ខោនស្រមោលស្បែកធំ ល្ខោនស្រមោលស្បែកតូច។ ឯវិស័យសិល្បៈចម្លាក់-គំនូរ យើងឃើញមានឆ្លាក់ជារូបទេពឬរូបតួអង្គដទៃទៀតក្នុងរឿង(ហនុមាន ពាលី សុគ្រីព ទូភី...) នៅលើថៃវ សសរផ្តែ ឬហោជាងប្រាសាទបុរាណ ឬគូរជាគំនូរនៅតាមវិហារវត្តអារាមពុទ្ធសាសនា ឬឆ្លាក់រូបតួអង្គរឿងរាមកេរ្តិ៍នៅជាប់

(2) សូមមើល អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប, (២០០៧), *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ*, ផ្សាយដោយហនុមានទេសចរណ៍ : ទំព័រ១២-១៣។

នឹងវត្ថុសក្ការៈបូជាឬសម្ភារៈប្រើប្រាស់ផ្សេងៗមានផ្ដិល ភាជន៍ ព្រះខ័ន។ល។ ចំណែកនៅក្នុងសិល្បៈចម្រៀងឬសិល្បៈភាពយន្តវិញក៏ទទួលរងឥទ្ធិពលពីរឿងរាមកេរ្តិ៍ផងដែរ ដូចជាចម្រៀងល្ខោនហ្លួង និងរឿងរាមកេរ្តិ៍ដែលថតជាអក្សរសិល្បភាពយន្ត។

**៤.១.៣- តម្លៃក្នុងវិស័យកីឡា**

វិស័យកីឡានៅទីនេះ យើងសូមលើកតែចំពោះកីឡាប្រដាល់មកនិយាយតែប៉ុណ្ណោះ។ ដូចយើងដឹងហើយថា ដំណើររឿងរាមកេរ្តិ៍ខ្សែ១-១០បានបង្ហាញពីវិវាទទំនាស់មិនចេះចប់មិនចេះហើយរវាងក្រុមតួអង្គតំណាងសភាវៈល្អនិងក្រុមតួអង្គតំណាងសភាវៈអាក្រក់ តួអង្គស្វានិងស្វា ឬក្របីនិងស្វា ជាដើម។ ដូច្នេះ នៅក្នុងកិច្ចការសង្គ្រាមតទល់គ្នាទៅវិញទៅមកនេះ យើងឃើញតួអង្គទាំងពីរខាងប្រកបដោយឫទ្ធិអំណាចដ៏ខ្លាំងសម្បើម ប្រើស្នៀតក្បាច់ផ្សេងៗដើម្បីកាច់យកឈ្នះគ្នាតែរៀងខ្លួន។ តួយ៉ាងដូចឈុតឆាកប្រកួតគ្នារវាង**ពាលីនិងទូភី**(*...ពាលីស្ដេចហិចហោះផ្សង ចរចេញយុទ្ធផង នូវក្រុងទូភីមហិមា។ ស្ដេចប្រយុទ្ធនូវរាជមហិង្សា ពីប្រឋម សុរិយា លុះអស្ដង្គតបាត់ថ្ងៃ។ សឹងជាញរឿណរង្គដ៏ទីទៃ ពុំលុះនាក្សយ័ ជីវិតនោះមួយៗណា។*[3]...) **ពាលីនិងសុគ្រីព**(... *ក្សិណរាជពាលីស្ទុះស្ទែង ចាប់សុគ្រីពខែង ក៏កាន់នូវត្បូងដ៏គ្រវី។ បោះបោកវាត់វាយនូវឫទ្ធី ពាលីរាជដ៏ក្របុី គ្រវីអនុជស្ទើរក្សយ័។*[4]...) ឬ**ព្រះលក្ស្មណ៍និងឥន្ទ្រជិត***(... ឥន្ទ្រជិតទ្រើសទ្រង់ធនូសា- ហ័សចេញបែកជា ន្ទេះនូវភ្លៀងដោរជេល។ ព្រះលក្ស្មណ៍ទ្រង់តេជោពល ផ្លែងសរជាខ្យល់ វាតាក៏បក់ខ្ចាយខ្ចាត់*[5])។

ដំណើរប្រយុទ្ធគ្នាដ៏ស្រួចស្រាវនៃតួអង្គនិងនាមតួអង្គទាំងអម្បាលនៅក្នុងរឿងខាងលើ បានជះឥទ្ធិពលនិងបន្សល់ទុកជាមរតកសម្រាប់សង្គមកម្ពុជារហូតដល់សព្វថ្ងៃនេះ តួយ៉ាងមានក្បាច់គុននិងរបៀបថ្វាយបង្គំគ្រូនៅមុនពេលកីឡាករប្រដាល់ចាប់ផ្ដើមប្រដាល់ ឬកិច្ចហាត់សម្ដែង ឬកិច្ចប្រកួតគុនផ្សេងៗ ដូចឃើញឃើញមានឈ្មោះខាងក្រោម៖

| ឈ្មោះគុន | | |
|---|---|---|
| ល.រ. | ឈ្មោះក្បាច់(គុនល្បុក្កតោ) | ឈ្មោះតួអង្គ |
| ១ | ក្បាច់ក្របី ឬតួរភី ឬក្របីរុលនឹម | ទូភី |
| ២ | ក្បាច់ក្របីបុកនឹម | ក្របី(ទូភី) |
| ៣ | ក្បាច់ហនុមានបំបាក់ភ្នំភ្លើង | ហនុមាន |
| ៤ | ក្បាច់ដំហរគ្រុឌ | គ្រុឌ |
| ៥ | ក្បាច់តួរភីបំបែកដំបូក | ទូភី |
| ៦ | ក្បាច់ស្វាបេះសេដា ថ្វាយព្រះរាម | ព្រះរាម |

| ឈ្មោះរបៀបបង្គំគ្រូ | | |
|---|---|---|
| ល.រ. | របៀបបង្គំគ្រូ | ឈ្មោះតួអង្គ |
| ១ | របៀបព្រះលក្ស្មណ៍ព័ទ្ធសីមា | ព្រះលក្ស្មណ៍ |
| ២ | របៀបព្រះរាមផ្លែងសរ | ព្រះរាម |
| ៣ | របៀបក្រុងរាពណ៍សម្ដែងឫទ្ធិ | ក្រុងរាពណ៍ |
| ៤ | របៀទូភីលេងស្នែង | ទូភី |
| ៥ | របៀបទូភីសម្ដែងឫទ្ធិ | ទូភី |
| ៦ | របៀបហនុមានសម្ដែងឫទ្ធិ | ហនុមាន |

[3] ពុទ្ធសាសនបណ្ឌិត្យ, (គ.ស.១៩៩៥), *រាមកេរ្តិ៍ខ្សែទី៥*: ទំព័រ១៧។

[4] *-ដ.ឯ.ម-,*: ទំព័រ៤០។

[5] ពុទ្ធសាសនបណ្ឌិត្យ, (គ.ស.១៩៩៥), *រាមកេរ្តិ៍ខ្សែទី៩*: ទំព័រ៣៨។

**៤.១.៤- តម្លៃក្នុងវិស័យដាក់ឈ្មោះ**

*ឈ្មោះ* មានសារៈសំខាន់ម្យ៉ាងក្នុងការបង្ហាញឱ្យយើងដឹងពីអត្តន័យ អត្តសញ្ញាណ ទស្សនៈផ្នត់គំនិត ឬចំណង់ចំណូលចិត្ត។ល។ យើងតែងសង្កេតឃើញថា ទំនោរនៃការដាក់ឈ្មោះមនុស្ស សម្ភារៈប្រើប្រាស់ ឈ្មោះទីកន្លែង ឬឈ្មោះម្ហូបអាហារផ្សេងៗ ច្រើនយោលទៅតាមពេលវេលា រណ្ដំឈ្មោះសាច់ញាតិ ឈ្មោះអ្នកសិល្បៈល្បីៗ ឈ្មោះរុក្ខជាតិ ឬដាក់ទៅតាមឈ្មោះតួអង្គក្នុងអក្សរសិល្ប៍។ ផ្ទៀងផ្ទាត់ឈ្មោះតួអង្គក្នុងរឿងរាមកេរ្តិ៍ យើងឃើញថាមានឥទ្ធិពលលើវិស័យដាក់ឈ្មោះនាមមួយចំនួនក្នុងសង្គមខ្មែរជាប្រាកដ។ ជាក់ស្ដែងទូកប្រណាំង[(6)] ឈ្មោះថា*អាវៃពណ៌ត្បូងឃ្មុំ*( តួអង្គក្នុយក្រុងរាពណ៍ ) *ហនុមានមានឫទ្ធិ*( តួអង្គហនុមាន ) និង*ហនុមានតេជោសែនជ័យបារមីពោធិ៍មាស*( តួអង្គហនុមាន ) សុទ្ធតែមានរំលេចឈ្មោះតួអង្គក្នុងរឿងរាមកេរ្តិ៍។ ចំណែកឈ្មោះរុក្ខជាតិ[(7)]ដូចយ៉ាងរុក្ខជាតិឈ្មោះ *លំពែងព្រះរាម*( តួអង្គព្រះរាម ) *សុកព្រះរាម*( តួអង្គព្រះរាម ) និង*សៃដា*( តួអង្គសីតា ) ជាដើម។

**៤.១.៥- តម្លៃក្នុងវិស័យនយោបាយ**

ប្រសិនយើងគ្រាន់តែបានអាន ទស្សនា ឬស្ដាប់ដំណើររឿងរាមកេរ្តិ៍ ដោយមិនបានគិតពិចារណា យើងអាចនឹងយល់ត្រឹមថារឿងនេះនិយាយត្រឹមតែការលើកសរសើរអាទិទេពសាសនាព្រាហ្មណ៍ ចម្បាំងអាទិទេពនិងអសុរៈ ឬបកស្រាយពីដំណើរជីវិតតួអង្គព្រះរាមនិងព្រះញាតិវង្សតែប៉ុណ្ណោះ។ ក៏ប៉ុន្តែប្រសិនយើងគិតពិចារណាឬវិភាគលើសាច់រឿងបន្តិចឬជ្រៅជ្រះជាងនេះ យើងនឹងឃើញខ្លឹមសារសំខាន់ៗជាច្រើនទៀតដែលគួរមានប្រយោជន៍ដល់ការក្នុងវិស័យផ្សេងៗ ជាអាទិ៍វិស័យនយោបាយជាដើម។

- **វប្បធម៌សន្ទនា :** *វប្បធម៌សន្ទនា* គឺជាមាគ៌ាមួយដ៏ប្រសើរដែលបង្ហាញពីភាពចាស់ទុំ ទស្សនៈប្រជាធិបតេយ្យ ការបញ្ចេញមតិយោបល់ និងគួរគេគោរពសរសើរ ពិសេសចំពោះតួអង្គនយោបាយ។ សន្ទនា មានន័យថាបើកចិត្តគំនិតស្ដាប់យោបល់គ្នា ពិភាក្សាមតិគ្នាដើម្បីរកដំណោះស្រាយល្អ ឬដើម្បីបានប្រយោជន៍រួមទាំងអស់គ្នា។ ក្នុងរឿងរាមកេរ្តិ៍ យើងពិនិត្យឃើញមានខ្លឹមសារទាក់ទងនឹងវប្បធម៌សន្ទនាដែរ គឺមុនកើតសង្គ្រាមនៅនគរលង្កា ព្រះរាមបានចាត់អង្គទធ្វើជារាជទូតនាំសារទៅក្រុងលង្កាដើម្បីប្រាប់ក្រុងរាពណ៍ឱ្យដឹងពីបំណងរបស់ព្រះរាម ដូចមានឃ្លាកំណាព្យ "*រីឯព្រះបាទរាមា ប្រើអញមកថា សំណេះនឹងទសមុខមារ។ ចូរស្ដាប់ព្រះរាជឱង្ការ ព្រះអាជ្ញាសារ សម្ដេចឥសូរថ្លៃថ្លៃ។...បទទសមុខមារចោរធ្ងន់ លបលួចសម្ពន្ធ ទេពីទេពតាសព្វសាយ* [(8)]។ ដូចគ្នានេះ នៅក្នុងសង្គមខ្មែរ កន្លងមកយើងក៏តែងសង្កេតឃើញតួអង្គនយោបាយបានប្រើវប្បធម៌សន្ទនាជាមួយគ្នាម្ដងម្កាលដែរ។
- **ឧត្តមគតិជាតិ :** យើងអាចនិយាយបានថា *ជាតិ* គឺជាចង្កោមរួមនៃមនុស្ស ទឹកដី វប្បធម៌-អរិយធម៌

---

(6) លោកគ្រូ ព្រាប ចាន់ម៉ារ៉ា ធ្លាប់បានធ្វើបាឋកថាស្ដីអំពី "*ឥទ្ធិពលរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ* នៅមជ្ឈមណ្ឌលបុប្ផាណា។ សូមរកមើល : https://youtu.be/g8CNZnsuRZY

(7) ព្រាប ចាន់ម៉ារ៉ា, (ឆ្នាំ២០០៩-ឆ្នាំ២០១០), *ឈ្មោះតួអង្គរឿងរាមកេរ្តិ៍នៅក្នុងរុក្ខជាតិ*, អត្ថបទចុះក្នុងកម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, ផ្សាយដោយយសោធរ : ទំព័រ៩៨-១០០។

(8) ពុទ្ធសាសនបណ្ឌិត្យ, (គ.ស.១៩៩៥), *រាមកេរ្តិ៍ ខ្សែទី៨* : ទំព័រ៦៣-៦៤។

(ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ ភាសា អក្សរ...) ឬជាអាយុជីវិតប្រជាពលរដ្ឋនៃប្រទេសមួយ។ ប្រសិនបើប្រជាពលរដ្ឋនៃជាតិសាសន៍មួយខិតខំអភិវឌ្ឍន៍ខ្លួនឱ្យរឹងមាំនិងមានឧត្តមគតិជាតិ ស្នេហាជាតិ លះបង់ដើម្បីជាតិ សាមគ្គីភាពជាតិ ឬភាតរភាពជាតិ ជាតិនោះក៏គង់នឹងបានរឹងមាំ ព្រមទាំងអភិវឌ្ឍន៍ឋិតថេរចីរកាលតទៅ។ តួយ៉ាងតួអង្គ **ពាលី** ជាថ្នាក់ដឹកនាំស្រឡាញ់ប្រទេសជាតិ សុខចិត្តស្លាប់មិនចំណុះព្រះរាមដាច់ខាត គឺដើម្បីការពារប្រទេសជាតិ ការពារនិងមិននាំទុក្ខលំបាកដល់ប្រជាពលរដ្ឋស្វា។ តួអង្គ **កុម្ភកាណ៌** ហេតុតែស្រឡាញ់ជាតិ គោរពតាមថ្នាក់ដឹកនាំ(ក្រុងរាពណ៍) មិនត្រចៀកស្រាលឬមិនព្រមទៅចុះចូលនឹងព្រះរាមតាមការអូសទាញរបស់ពិភេកឡើយ។ ផ្ទុយមកវិញ ប្រសិនបើថ្នាក់ដឹកនាំឬប្រជាពលរដ្ឋបែកបាក់គ្នា ឬចុះចូលដៃជារនុកក្នុងរបស់សត្រូវ ប្រាកដណាស់ថា ជាតិនោះនឹងមិនបានសុខ បែកបាក់ ឈានទៅវិនាសអន្តរាយជាមិនខាន។ ងាកមករឿងរាមកេរ្តិ៍ មិនខ្វះទេតួអង្គ ដែលប្រកបដោយឧត្តមគតិជាតិ។ ដូចយ៉ាងតួអង្គ **សុគ្រីព** ដែលទទួលរងរឿងយល់ច្រឡំឬអយុត្តិធម៌ពីនគរខ្លួន បង្កបានជាការមិនសុខចិត្ត ហើយទៅចុះចូលនឹងព្រះរាមប្រឆាំងតបតនឹងពាលីជាបងរបស់ខ្លួន ជាហេតុបណ្តាលឱ្យពាលីស្លាប់និងបង្កទុក្ខលំបាកដល់រាស្ត្រនៅនគរខ្លួន។ ម្យ៉ាងទៀតតួអង្គ **ពិភេក** ព្រោះតែផ្តល់យោបល់ទៅបង(ក្រុងរាពណ៍) តែរាពណ៍មិនស្តាប់ ហើយថែមទាំងខឹងច្រឡោតដោះស្បែកជើងវាយក្បាលពិភេកនៅក្នុងចំណោម ពិភេកក៏ងាកទៅចុះចូលនឹងព្រះរាម ជួយផ្តល់យោបល់ជូនព្រះរាម នាំឱ្យក្រុមខាងព្រះរាមនិងព្រះរាមមានជ័យជម្នះក្នុងសង្គ្រាម រហូតនគរលង្កាជាអតីតនគរកំណើតខ្លួនត្រូវវិនាសសាបសូន្យ។

○ **នយោបាយកៀងគរអ្នកពូកែ** : អ្នកដឹកនាំឈ្លាសវៃ គួរគប្បីស្រឡាញ់ធនធានពូកែៗឬធនធានមានសមត្ថភាព ដោយគួររកមធ្យោបាយអូសទាញឬកៀងគរដោយធម៌ត្រូវ និងចេះប្រើប្រាស់ឱ្យត្រូវតាមមុខជំនាញ។ រឿងរាមកេរ្តិ៍បានបង្ហាញថា ព្រះរាមជាថ្នាក់ដឹកនាំដែលស្រឡាញ់អ្នកខ្លាំងពូកែឬអ្នកមានសមត្ថភាព។ តួយ៉ាងព្រះរាមបានចាត់ឱ្យអង្គទនិងហនុមានទៅបញ្ចុះបញ្ចូល**មហាជម្ពូ** ឱ្យមកស្ម័គ្របម្រើទ័ពខាងព្រះរាម។

○ **ឧបាយកលយកឈ្នះគូប្រកួត** : នៅក្នុងកិច្ចប្រកួតប្រជែងការអ្វីមួយ ដើម្បីអាចយកឈ្នះលើគូប្រកួត តោងត្រូវពង្រឹងសមត្ថភាពខ្លួនឱ្យពូកែ ឬព្យាយាមសង្កេតពិនិត្យនិងស្គាល់សមត្ថភាពដៃគូឱ្យច្បាស់ និងចេះមានកលល្បិចយកឈ្នះលើសត្រូវ។ តាមដំណើររឿងរាមកេរ្តិ៍ខ្សែទី៥ នៅពេល**ពាលី**និង**ទូភី**ប្រកួតល្បងឫទ្ធិគ្នានៅទីវាលតាំងពីព្រឹករហូតថ្ងៃលិច ដោយគ្មានអ្នកណាឈ្នះសោះ ពាលីបានរៀបចំកលល្បិចបបួលទូភីទៅប្រយុទ្ធគ្នាក្នុងរូងភ្នំ រហូតសម្លាប់ក្របីទូភីបាន។ តាមជាក់ស្តែង យើងអាចគិតយល់ថារូងភ្នំចង្អៀតជាងទីវាល ដូច្នេះទីស្ថានប្រយុទ្ធនេះបានផ្តល់លទ្ធភាពឈ្នះច្រើនទៅខាងពាលី។

### ៤.១.៦- តម្លៃក្នុងវិស័យយុត្តិធម៌

○ **តម្លៃពាក្យសត្យ** : ពាក្យសត្យ គឺពាក្យពិត ពាក្យទៀងត្រង់ពាក្យមិនភូតកុហក។ មិនថានៅក្នុងសង្គមឥណ្ឌាឬសង្គមខ្មែរ ពាក្យពិតគឺមានតម្លៃដល់ការដែលគេគួរគោរព។ ប្រសិនយើងពោលឬនិយាយបែបណា តោងប្រកាន់ខ្ជាប់បំពេញតាមសម្តីឱ្យបាន ហើយរឹងរឹតតែសំខាន់ចំពោះបុគ្គលជាថ្នាក់ដឹកនាំគេ។ ដ្បិតថាមានពាក្យពិត

ខ្លះវែងគ្រោតគ្រាត មិនពីរោះពិសា ឬមិនជាទីគាប់ចំពោះជនចំពូកណាមួយដូចពំនោលបុរាណថា *"ពាក្យពិតវែងស្លែង"* ក៏ប៉ុន្តែប្រសិនបើភូតកុហកក៏មិនអាចយកជាការបានដូចពំនោលថា *"ភូតច្រើនចាញ់អាត្មា"*។ ឆ្លុះតាមរយៈរឿងរាមកេរ្តិ៍ យើងឃើញតម្លៃពាក្យសត្យលើពីរចំណុចធំៗគឺ **ពាក្យសត្យរបស់ព្រះបាទទសរថ** ដូចយើងដឹងថាកាលព្រះបាទទសរថច្បាំងឈ្នះសង្គ្រាម ព្រះអង្គបានសន្យានឹងនាងកៃកេសីថានឹងលើកព្រះភិរុតបុត្រានាងកៃកេសីឱ្យស្នងរាជសម្បត្តិតពីព្រះអង្គ។ ប៉ុន្តែដំណើរនេះបានផ្ទុយនឹងបវេណីពីបុរាណផង(ប្អូនមិនអាចសោយរាជ្យមុនបង) ហើយព្រះអង្គពេញព្រះទ័យចំពោះព្រះរាមដែលជាបុត្រាច្បងប្រកបដោយលក្ខណៈសម្បត្តិផង។ ជាលទ្ធផលតម្លៃពាក្យសត្យនៅតែមាន គឺព្រះរាមព្រមយាងចូលព្រៃដើម្បីបំពេញពាក្យសត្យបិតា។ ដោយឡែកនៅខ្សែទី៨០ បានបង្ហាញពី **ពាក្យសត្យរបស់ព្រះនាងសីតា** ដែលព្រះនាងបានតាំងប្រកាសសច្ចាថាដរាបព្រះរាមសុគត ទើបព្រះនាងវិលចូលនគរដើម្បីបង្គំព្រះសព។ ក្រោយមកដោយដឹងពីកលល្បិចព្រះរាមធ្វើជាសុគត ព្រះនាងក៏ឈប់យំសោកនៅមុខកោដ្ឋក្លែងក្លាយរបស់ព្រះរាម ហើយរក្សាពាក្យសត្យរបស់ខ្លួន រត់គេចចេញរហូតព្រះធរណីជ្រែកជាពីនាំយកព្រះនាងទៅឋានកុដង្គនាគ។ ចំណែកឯ**ពាក្យមុសា ភូតកុហក** ពិតជាចាញ់អាត្មាខ្លួនមែន ដូចយ៉ាងព្រះរាមបានរៀបចំកលល្បិចកុហក បោកបញ្ឆោតមហេសីខ្លួន ដើម្បីបានមូលត្រសូលរស់ជួបជុំគ្នាវិញ ក៏ប៉ុន្តែព្រះអង្គរឹងរឹតតែបាត់បង់មហេសីកាន់តែឆ្ងាយទៅៗ។

○ **អំពើល្អនិងអំពើអាក្រក់** : មិនថានៅក្នុងព្រាហ្មណ៍សាសនាឬពុទ្ធសាសនា អំពើល្អតែងឈ្នះលើអំពើអាក្រក់។ យើងច្រើនដឹងគ្រប់គ្នាថា បញ្ចប់រឿងនៅក្នុងអក្សរសិល្ប៍ព្រាហ្មណ៍និយម គឺសភាវៈល្អមានជ័យជម្នះលើសភាវៈអាក្រក់។ រឿងរាមកេរ្តិ៍ មួយផ្នែកធំគឺលាតត្រដាងពីសង្គ្រាមរវាងក្រុមតួអង្គតំណាងអាទិទេពនិងក្រុមអសុរៈ។ ផ្អែកតាមដំណើររឿងជាក់ស្តែង បញ្ហាទំនាស់សង្គ្រាមគឺមកពីក្រុមអសុរៈឬយក្សដែលតំណាងសភាវៈអាក្រក់ ហើយតែងដើរបៀតបៀន យាយី ធ្វើទុក្ខបុកម្នេញ គំរាមកំហែងគេឯងមានមនុស្ស សត្វ រាប់ទាំងអាទិទេពផងដែរ។ ប៉ុន្តែបើឈរលើទស្សនៈសាសនាវិញ យើងអាចនិយាយបានថាទំនាស់រវាងអាទិទេពនិងអសុរៈ គឺដើម្បីបំពេញតួនាទីរបស់អាទិទេពដែលត្រូវចុះមកកម្ចាត់សភាវៈអាក្រក់។ តួអង្គសីតា មិនបានប្រព្រឹត្តក្បត់ដូចការចោទប្រកាន់របស់ព្រះរាម(ដោយសារគូររូបរាពណ៍) ទោះព្រះលក្ស្មណ៍លើកព្រះខ័នកាត់ព្រះសិររបស់ព្រះនាងម្តេចក្តី ប៉ុន្តែបានត្រឹមក្លាយជាកម្រងផ្កាទៅវិញ។ មិនតែប៉ុណ្ណោះ ព្រះនាងថែមទាំងបានទេវតាជួយអន្តរាគមន៍និងនាំបង្ហាញផ្លូវរហូតបានដល់អាស្រមរបស់ឥសីវជ្ជប្រិតថែមទៀត។ ចំណែកតួអង្គរាពណ៍បានប្រព្រឹត្តអាក្រក់លួចចាប់ប្រពន្ធអ្នកដទៃរួមទាំងសីតាមហេសីព្រះរាមផង ចុងក្រោយត្រូវវិនាសក្រុងលង្កា ស្លាប់ព្រាត់ប្រាសកូន និងបង្កទុក្ខលំបាកដល់រាស្ត្រនៅនគរ ដោយសារតែអំពើអាក្រក់និងភាពមានះរឹងរូសរបស់ខ្លួន។

### ៤.២- តម្លៃផ្នែកអត្ថរូប

#### ៤.២.១- តម្លៃសោភ័ណ

ដូចយើងដឹងហើយថា អត្ថបទសំណេររឿងរាមកេរ្តិ៍បាននិពន្ធឡើងជាកំណាព្យ សរុបមានចំនួន៦៦៩៣

៦៦៩៣ល្បះ(ខ្សែ១-១០ចំនួន៤៩២៤ល្បះ និងខ្សែ៧៥-៨០ចំនួន១៧៦៩ល្បះ)។ អត្ថបទរឿងរាមកេរ្តិ៍មានសម្ផស្សពាក្យពេចន៍ភាសាខ្មែរបុរាណនិងកណ្ដាល លាយឡំនឹងភាសាសំស្ក្រឹត-បាលី ប្រកបដោយចំណាប់ចុងចួនពីរោះរណ្ដំណែងណង ក្នុងការលាតត្រដាងពីសកម្មភាព ឫទ្ធិអំណាចតួអង្គ ឬទេសភាពធម្មជាតិតាមទីឋាននានា ព្រមទាំងមានភ្ជាប់ឈ្មោះសម្រាប់សូត្រឬពោល ពិសេសពេលយករឿងនេះទៅសម្ដែងដែលបង្កើតបានជាសោភ័ណទស្សនីយភាពសិល្បៈដ៏ល្អបណ្ដាច់។

## ឈ្មោះបទក្នុងរឿងរាមកេរ្តិ៍[9]

| ល.រ. | ឈ្មោះបទ | | ល.រ. | ឈ្មោះបទ | |
|---|---|---|---|---|---|
| ១ | បទសំរើប | ដើតបទថយ៉យ | ២០ | ដើតបទរាយ | បទភ្លម់បទរាយ |
| ២ | សំណារខរ | ដើតបទឡើងរថ | ២១ | ដើត រាយ | បទភ្លម់ បទពិលាប |
| ៣ | សំណារខម | បទបំរើ | ២២ | ដើត បទរាយដោន | និយាយបទរាយ |
| ៤ | សំណារស្ដេចលេលា | បទប្រគំ | ២៣ | ដើត ភ្លេងបទរាយ | និយាយដើតបទរាយ |
| ៥ | សំណារខ្មែរ | បទធា | ២៤ | ដើតឱតបទរាយ | និយាយឯកបទ |
| ៦ | សំណារសៀម | បទទ្រង់គ្រឿង | ២៥ | និយាយបទឱត | បទពិលាប |
| ៧ | សំណារសៀមសុទ្ធ | បទឆ្នានបទជុំព្រៃ | ២៦ | និយាយពិលាបបទរាយ | ពញាសោកបទស្មើងថង |
| ៨ | សំណារ | បទច្រះដុក | ២៧ | និយាយស្មើបទរាយ | ពញាបទរាយ |
| ៩ | សំណារលា | បទដណក | ២៨ | ភ្លេងបទរាយ | បទធា |
| ១០ | សំណារមន | បទឱត | ២៩ | ភ្លេងថយ៉យឱតរាយ | បទនិយាយ |
| ១១ | សម្ដេចភាណ | ឱតបទពិលាប | ៣០ | ភ្លេងពញាដើរបទរាយ | បទក្រៅណកបទទ្រង់គ្រឿង |
| ១២ | សម្ដេច | ឱតបទរាយ | ៣១ | ភ្លេងបទជុំព្រៃ | ក្រៅលាកបទរាយ |
| ១៣ | សម្ដេចលេលា | ឱតបទរាយ | ៣២ | ភ្លេងបទទួងព្រះធាតុ | ត្រះរាយ |
| ១៤ | សម្ដេចលា | ឱតបទនិយាយ | ៣៣ | ភ្លេងត្រះ បទរាយ | ត្រះភ្លេងបទសម៉យ |
| ១៥ | ដើត | ឱតបទរាយពិលាប | ៣៤ | ភ្លេងខោម បទរាយ | បទណនសី |
| ១៦ | ដើតហើយច្រះ | បទឱតលោម | ៣៥ | ភ្លេងត្រះរាយ | បទឆ្នានបទរាយ |
| ១៧ | ដើតច្រះ | បទរាយ | ៣៦ | ភ្លេងធា បទរាយ | ស្មើបទរាយ |
| ១៨ | ដើតហើយច្រះដុក | បទត្រះបទរាយ | ៣៧ | បទយានី | ឆន្ទបទរាយ |
| ១៩ | ដើតបទខឹងមាំ | បទស្មើបទរាយ | | | |

(9) សូមមើល លាង ហាប់អាន, *រឿងរាមកេរ្តិ៍*, ទំព័រ៩០,៩១,៩២។

### ៤.២.២- តម្លៃសិល្បវិធីតែងនិពន្ធ

រឿងរាមកេរ្តិ៍បានរំលេចនូវសិល្បវិធីតែងនិពន្ធដ៏សម្បូរបែប ដែលអាចចាត់ទុកជាលំអាន គំរូ តឹកតាង និង បង្ហាញពីសមត្ថភាពសិល្បៈខ្ពស់របស់អ្នកនិពន្ធខ្មែរ។

### ៤.២.២.១- វិធីតែងនិពន្ធ

វិធីតែងនិពន្ធ គឺជារបៀប បែបបទ ក្បួនខ្នាត បច្ចេកទេស ឬជាសិល្បវិធីដែលអ្នកនិពន្ធប្រើប្រាស់នៅក្នុង ការសរសេររឿងឬតាក់តែងរឿង ដើម្បីឱ្យអត្ថបទរឿងទាំងមូលមានសោភ័ណ មានខ្លឹមសារល្អ និងទាក់ទាញអ្នក អាន។ ចំពោះរឿងរាមកេរ្តិ៍ យើងសង្កេតពិនិត្យឃើញមានសិល្បវិធីតែងនិពន្ធច្រើនបែបយ៉ាងណាស់ ប៉ុន្តែស្នេរសូម លើកយកខ្លះៗមកបង្ហាញតែប៉ុណ្ណោះ។

**ក- សញ្ច័យវិធី** : គឺជាវិធីតែងនិពន្ធមួយបែបដែលកវីឬអ្នកនិពន្ធប្រមូលផ្តុំនូវភេទការណ៍ ឬមតិផ្សេងៗក្នុងវគ្គ ឬ ប្រយោគតែមួយ។ គេច្រើនផ្តុំប្រធាន កិរិយាសព្ទ ដើម្បីបង្ហាញឱ្យឃើញនូវចលនាឆាប់រហ័ស រំភើបញាប់ញ័រ។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី៤ ទំព័រ៣២ បង្ហាញពីសកម្មភាពប្រហាររបស់ព្រះរាមលើក្រុងខរៈ

"... *ស្តេចដំស្តេចជាន់ស្តេចជាក់ ស្តេចប្រានស្តេចចាក់ ស្តេចហែករុះរោយបោះបង់*"...។

**ខ- បុនរុត្តិវិធី** : ជាវិធីតែងនិពន្ធមួយបែបដែលកវីឬអ្នកនិពន្ធធ្វើឱ្យផ្ទួនពាក្យសម្តីឬផ្ទួនមតិដដែលៗ ដើម្បីឱ្យមាន ចលនា សកម្មភាព របស់តួអង្គកាន់តែជាក់ស្តែងឡើង។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី៣ ទំព័រ១២ មានឈុតមួយបង្ហាញពីក្រុងខរបានរៀបចំទ័ពចេញតាំងយុទ្ធនឹងព្រះរាមៈ

"... *សឹងជិះនូវដំរិះចេញចរ ជិះនាគជិះមករ ខ្លះជិះដំរិះម្រឹគា។*
*ជិះគោជិះគោមហិង្សា ខ្លះជិះលៀងភា ខ្លះសោតក៏ជិះរាជសីហ៍។*
*ខ្លះជិះសេះនូវក្របី ជិះគជហត្ថី ដំរីមាសខ្លោងខ្លា។* "...

**គ- និយមេតិវិធី** : ជាវិធីតែងនិពន្ធមួយបែបដែលកវីឬអ្នកនិពន្ធ ប្រើដោយធ្វើឱ្យព្យាង្គនៃពាក្យចុងឃ្លាណាមួយលោត ទៅតជាប់នឹងព្យាង្គដើមនៃឃ្លាបន្ទាប់ ដើម្បីបន្តគំនិតកុំឱ្យដាច់ចេញពីគ្នា និងឱ្យកំណាព្យមានលក្ខណៈត្រឹមត្រូវក្នុង ការរៀបចំឃ្លាឱ្យគ្រប់ចំនួនព្យាង្គ។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី២ ទំព័រ៧៩ បានបង្ហាញពីនិយមេតិវិធី(ឬវិធីយត្តិកង្គ)ដូចខាងក្រោមៈ

"...*ភ័ពមួយនាសោតិ -ន្ទ្រិយ៍ទេង់ឥន្ទ្រិយ៍សោតសល់ ស្រោតត្រេកវិញ្ញាណស្គាល់ ឮព្រះសូរមធុរសា។*
*ភ័ពមួយនាឃានិ -ន្ទ្រិយ៍អាចិន្ត្រៃយត្រកាល នាសិកសោតគន្ធា ជុំសុគន្ធសុមាលា។*

**ឃ- វេសម្មវិធី** : ជាវិធីតែងនិពន្ធមួយបែប ដែលកវីឬអ្នកនិពន្ធចេះលើកយកគុណភាពពីរ ចលនាឬសកម្មភាពពីរ សំនួនសេចក្តីពីរ មតិទស្សនៈពីរ ឬអត្តខាងក្នុងនិងខាងក្រៅរបស់តួអង្គណាមួយ ដែលមានភាពផ្ទុយគ្នាមកដាក់ ប្រៀបគ្នាដើម្បីពន្លេចឱ្យឃើញពីតម្លៃមួយ។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី១ ទំព័រ៤២ បានបង្ហាញពីភាពផ្ទុយគ្នារវាងរូបសម្បត្តិខាងក្រៅនិងចិត្តគំនិតខាងក្នុង

របស់កូខ័នដូចខាងក្រោម៖

"... *រីកូខ័នមោះហិមា　　　រូបរូបឮតា　　　ស្រមើងស្រមាក់ស្ទឹមស្ដែ។*

*សក្តិសួនជាអ្នកថ្មើរព្រៃ　　　ខ្លួនខ្មៅក្រៅវិស័យ　　　នូវធ្មេញសស្ទឹមភ្នែកប្រាល។* "...

**៤.២.២.២- វិធីបង្ហាញតួអង្គ**

នៅក្នុងផ្ទៃរឿងរាមកេរ្តិ៍ទាំងមូល យើងឃើញមានតួអង្គចម្រុះបែបផ្សេងគ្នាទាំងទេព មនុស្ស យក្ស ឥសី គ្រុឌ ស្វា ជាដើម ដែលរស់នៅទីឋានជាមួយគ្នាក៏មាន ទីឋានទីទៃពីគ្នាក៏មាន។ ប៉ុន្តែនៅក្នុងដំណើររឿង តួអង្គទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក ក្នុងន័យរួមមូលកម្លាំង ឬប្រឆាំងមានទំនាស់នឹងគ្នា។

**ក- វិធីបង្ហាញតួអង្គទេព** : ជាទូទៅ តួអង្គទេពយើងតែងឃើញបង្ហាញដោយឫទ្ធិអំណាច ដោយភាពអស្ចារ្យ ដោយសេចក្តីសាទរចំពោះរឿងអ្វីមួយ ឬដោយទេវន្តរាគមន៍ជាដើម។ រឿងរាមកេរ្តិ៍ជារឿងបែបព្រាហ្មណ៍និយម ដូច្នេះតែងមានរំលេចវត្តមានទេពជាចាំបាច់ ព្រមដោយការពោលគោរពសរសើរចំពោះទេពផង។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី១ ទំព័រ៧ បានបង្ហាញពីវត្តមានទេពកក្រើកអស់ត្រៃត្រឹង្សាព្រោះតែកិច្ចពិធីលើកធ្នូនៅនគរមិថិលា៖

ឧទាហរណ៍ : "... *ព្រះឥន្ទ្រស្តេចលើឮរា　　　អមរនាគេន្ទ្រា　　　រស្មីរុងរឿងគិតដ៏ថ្កើង។*

*ព្រះអគ្គីស្តេចលើមាសភ្លើង　　　តេជោជ័យថ្កើង　　　ឫទ្ធីមាសមោះហិមា។*

*ព្រះពាយផ្សាយផ្សព្វដ៏វេហាស៍　　　អស្សពាហន៍លេលា　　　គឺពាយក៏បក់បីប្រហារ។*"...

**ខ- តួអង្គមនុស្ស** : យ៉ាងណាមិញតួអង្គមនុស្សនៅក្នុងរឿងរាមកេរ្តិ៍ បង្ហាញច្បាស់ទាំងសាច់ញាតិ ទីនគររស់នៅ បញ្ហាទំនាស់វិបត្តិ បញ្ហាលោភលន់ បញ្ហាប្រចណ្ឌ ភូតកុហក ទុក្ខសោក ជាដើម។ ជាពិសេស ដំណើររឿងបានបង្ហាញច្រើនពីព្រះញាតិវង្សរបស់ព្រះរាម រួមជាមួយបញ្ហាចាក់ស្រេះដែលកើតមានឡើងដូចបានរៀបរាប់ខាងលើ។

**គ- វិធីបង្ហាញរុក្ខជាតិ** : ថ្វីដ្បិតឈ្មោះទីកន្លែងនៃរឿង មិនមានទីណាមួយបញ្ជាក់ពីទីកន្លែងស្រុកខ្មែរ ប៉ុន្តែអ្នកនិពន្ធបានរំលេចនូវសម្បត្តិធម្មជាតិ មានរុក្ខជាតិ សត្វជាតិជាដើមសុទ្ធតែមាននៅក្នុងស្រុកទេសខ្មែរយើង មកបង្ហាញប្រកបដោយកំណាព្យចុងចួនរណ្តំណៃងណង។ ដូចឃ្លាកំណាព្យក្នុងខ្សែទី៧៦ ទំព័រ៤៧ "*ទំពូងគ្រញូងសូក្រំលៀបលោតរាំងភ្នំក្រកោះ គ្រើលគ្រង់លំពង់លំពោះ ស្នាច់ស្នែជ្រៃជ្រៃស្តីស្តៅ។ ព្រីងព្រូសជន្លូសមាក់ប៉ែន សេរមាន់គូលែនបង្គៅ មាក់ប្រេងមាក់ប្រាងពិ្តលញ្ចៅ មង្ឃុតល្មុតសេដា*"។

**ឃ- វិធីបង្ហាញសត្វជាតិ** : ក្នុងការបង្ហាញសត្វជាតិ ក៏មិនខុសគ្នាពីរុក្ខជាតិប៉ុន្មានដែរ ពោលគឺអ្នកនិពន្ធបានលើកយកសត្វណាដែលច្រើនឋិតក្នុងសន្តានអម្បូរជាមួយគ្នាមករាយជាកំណាព្យបន្តបន្ទាប់គ្នាដែលសត្វទាំងនោះមានឈ្មោះប្រដំប្រសងណៃងណងឆ្លាស់គ្នាមិនដាច់។ ឧទាហរណ៍រាមកេរ្តិ៍ខ្សែទី៧៦ ទំព័រ៤៧ "...*រមាសរមាំងខ្លោងខ្លាចចកស្វានស្វាប្រើសទ្រាយ ទន្សងទន្សោងទន្សាយ រាជសីហ៍គជសីហ៍យុគា...*"។

### ៤.២.២.៣- រូបារម្មណ៍វិធី

**ក- ឧបមានរូបារម្មណ៍ :** ជារូបារម្មណ៍កើតឡើងដោយសារកវីប្រើពាក្យឬសំនួនពាក្យប្រៀបធៀប ដើម្បីប្រៀបប្រដូចភាវៈឬវត្ថុពីរ ដែលធ្វើឱ្យអារម្មណ៍អ្នកអាន អ្នកស្ដាប់ អ្នកទស្សនាហាក់ចូលទៅក្នុងស្ថានភាពនោះដែរ។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី២ ទំព័រ៣ "... *ឧបមាបុប្ផាពិពណ៌ ច្បានោះគឺផ្ទ័រ ក៏ឆេះកំឡុងភ្លើងច្រាល។ រីផ្កានទេងនៅកណ្ដាល ដូចសុពណ៌កាល រំលាយមាសមានស្មើ*"...។ តាមឧទាហរណ៍នេះ កវីប្រៀបធៀបអង្គទី១ ផ្កានទេងទៅនឹងអង្គទី២មាស។

**ខ- ឥន្ទ្រីយ៍រូបារម្មណ៍ :**

រាមកេរ្តិ៍ខ្សែ២ ទំព័រ៧៩ "...*ភ័ពមួយនាសោតិ -ន្ទ្រិយ៍ទ្រង់ឥន្ទ្រិយ៍សោតសល់ ស្រោតត្រេកវិញ្ញាណស្គាល់ឮព្រះសូរមធុរសោ។ ភ័ពមួយនាឃានិ -ន្ទ្រិយ៍អាចិន្ត្រៃយត្រកាល នាសិកសោតគន្ធា ជុំសុគន្ធសុមាលា។ ភ័ពមួយនាអង្គឥន្ទ្រិយ៍ជិវ្ហា អណ្ដាតដាលមុខា បានស្នេហ៍ស្នងបន្ទូលថ្លៃ។ ភ័ពមួយនាកាយិ -ន្ទ្រិយាចិណ្ណវណ្ណាស្រ័យខ្លួនខ្ញុំបានផ្សព្វនៃ ព្រះបាទប្រសើរវិសេសសាន្ត*"...។

## ៤.៣- តម្លៃផ្នែកអត្ថរស

### ៤.៣.១- អច្ឆរិយរស

អច្ឆរិយរស គឺជាតម្លៃដែលកើតចេញពីលក្ខណៈអស្ចារ្យរបស់តួអង្គ ដូចជាចេះហោះហើរ ចេះកាឡាខ្លួនពង្រីកបង្រួមកាយ សិល្ប៍មន្តអាគម ចេះដបចេះប្រោះ។ល។ ដោយរឿងរាមកេរ្តិ៍ជាប្រភេទអក្សរសិល្ប៍បុរាណដូច្នេះតម្លៃអច្ឆរិយរសនេះរមែងកើតមានជាធម្មតា។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី៩ ទំព័រ៣៨ បានបង្ហាញពីឈុតប្រយុទ្ធគ្នារវាងព្រះលក្ស្មណ៍និងឥន្ទ្រជិតៈ

"*ឥន្ទ្រជិតទ្រើសទ្រង់ធនូសា- ហ៍សចេញបែកជា រន្ទះនូវភ្លៀងដោរដល។*
*ព្រះលក្ស្មណ៍ទ្រង់តែជោពល ផ្លែងសរជាខ្យល់ វាតាក៏បក់ខ្ចាយខ្ចាត់។*"...

### ៤.៣.២- វីររស

វីររស គឺជាតម្លៃដែលកើតចេញពីលក្ខណៈអង់អាច ក្លាហាន មោះមុត ស្វាហាប់របស់តួអង្គ ដោយមិនរាថយចុះចាញ់(កាយ វាចា ចិត្ត) ចំពោះបញ្ហាណាមួយ។ តួអង្គក្នុងរឿងរាមកេរ្តិ៍ទោះជាតិទេពក្ដីក្ដី អសុរៈក្ដី មនុស្សក្ដី ឬសត្វក្ដី គឺសុទ្ធសឹងប្រកបដោយវីររស។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី៨ ទំព័រ៤៦ បង្ហាញពីឈុតដែលអង្គទនាំព្រះរាជអាជ្ញាព្រះរាមទៅលង្កាៈ

"*ដងនោះអង្គទទ្រើសឃ្នង ស្រេចលីលាផ្គង ទៅទៀបក្លាងមឿងមហិមា។*
*គ្រវីព្រះខ័នពេជ្រថ្លា គំរាមស្រែកថា ពះអង្គអសូរអញមក។*
*អញនូវចាប់អស់លង្កាត្បូក ក្បាលឱ្យពុរពេក ជ្រាមជ្រុះទាំងសក់សិរសា។*"...

**៤.៣.៣- តថរស**

តថរស គឺជាតម្លៃដែលកើតចេញពីការលើកយកតថភាពសង្គមមកបង្ហាញដូចជាបញ្ហាជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ ជីវភាពរស់នៅ ឬទំនាស់វិបត្តិផ្សេងៗ។

ឧទាហរណ៍ : តថរសក្នុងរឿងរាមកេរ្តិ៍ យើងពិនិត្យឃើញដូចជាការបង្ហាញពីទំនៀមច្រត់ព្រះនង្គ័លរបស់ស្តេចជនក វិបត្តិទំនាស់រាជសម្បត្តិក្នុងព្រះញាតិវង្សព្រះរាម បញ្ហាបែកបាក់គ្រួសាររបស់ព្រះរាម។ល។

**៤.៤.៤- ទស្សនីយរស**

ទស្សនីយរស គឺជាតម្លៃដែលកើតចេញពីការរៀបរាប់ឬការលើកយកទស្សនីយភាពធម្មជាតិ មានរុក្ខជាតិ បក្សាបក្សី សូរសព្ទធម្មជាតិ រួមទាំងសកម្មភាពមនុស្សផង មកបង្ហាញបង្កើតបានជាតម្លៃសោភ័ណលម្អដល់ចក្ខុ ឬសោតរូបារម្មណ៍របស់អ្នកអាន អ្នកស្តាប់ អ្នកទស្សនា។

ឧទាហរណ៍ : រាមកេរ្តិ៍ខ្សែទី២ ទំព័រ១ បានបង្ហាញពីទេសភាពធម្មជាតិដូចជា៖

*"មើលមានព្រៃព្រឹក្សសាខា សងខាងមាគ៌ា សឹងប្រែត្រដាក់ដ៏សប្បាយ។*
*លូតលាស់មាលាលេចលាយ ដុះដាសរៀងរាយ រូបានរបៀបអភិរម្យ។*
*ស្រោងស្រឹងឈរឈើងដង្គុម្ព ស្លឹកស្លោមបីត្រសុំ ត្រសាយត្រសៀកវ៉ាតា។"...*

**៤.៤.៥- កុសលរស**

កុសលរស គឺជាតម្លៃដែលលេចចេញតាមរយៈការអប់រំឬពាក្យទូន្មានប្រៀនប្រដៅ ដើម្បីឱ្យស្គាល់ល្អអាក្រក់ គុណទោស បុណ្យបាប។ រឿងរាមកេរ្តិ៍ មានតម្លៃអប់រំអនេកណាស់ ប៉ុន្តែស្នេរសូមបង្ហាញជូនត្រួសៗដូចតទៅ៖

- ត្រូវស្រឡាញ់ជាតិ មានឧត្តមគតិជាតិ រក្សាការពារជាតិ រួមគិតប្រយោជន៍ជាតិជាធំ (តួអង្គពាលីជាគំរូ)
- ត្រូវគោរពពាក្យសម្តី និយាយបែបណា តោងព្យាយាមធ្វើបែបនោះឱ្យបាន (ពាក្យសត្យព្រះបាទទសរថនិងពាក្យសត្យព្រះនាងសីតា)
- ជាយុវភាព តោងខិតខំរៀនសូត្រឱ្យបានល្អប្រសើរ (ព្រះរាមនិងព្រះលក្ស្មណ៍ធ្លាប់រៀនពីឥសីពិស្វាមិត្រ)
- កុំមានចិត្តលោភលន់ចំពោះទ្រព្យសម្បត្តិ អំណាចបុណ្យសក្តិដែលមិនគួរបានមកខ្លួន (ចៀសវាងយកគំរូតាមព្រះនាងកៃកេសី)
- កុំឆាប់មានចិត្តខឹង ដោយមិនបានគិតពិចារណាឱ្យវែងឆ្ងាយ ឬស្វែងយល់ការពិតជាមុន (ចៀសវាងប្រព្រឹត្តទង្វើដូចតួអង្គព្រះរាម ពិសេសនៅខ្សែទី៧៥ ដែលប្រចណ្ឌខឹងនឹងមហេសីដោយមិនពិចារណា)
- គប្បីចៀសវាងអំពើឃោឃៅ បៀតបៀន បង្កទុក្ខក្តៅក្រហាយដល់អ្នកដទៃ ព្រោះអាចនាំឱ្យវិនាសខ្លួន (ដូចយ៉ាងតួអង្គក្រុងរាពណ៍)
- អ្នកដទៃមានទុក្ខ គប្បីចេះជួយយកអាសារ ជួយសង្គ្រោះគេ (តួអង្គឥសីវជ្ជប្រិតជាគំរូ)។ល។

# ឯកសារពិគ្រោះ


ឃីង ហុកឌី, (២០០៤), *សាស្ត្រារាមកេរ្តិ៍ កាលវៃយោពណ៌សន្និយកព្រះរាមបាន*, បណ្ណាគារអង្គរ : ភ្នំពេញ។

ឃីង ហុកឌី, (២០០៣), *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*, បណ្ណាគារអង្គរ : ភ្នំពេញ។

ញ៉េប សែ, ហ៊ាង រិទ្ធ និង ចក់ ឫទ្ធី, (២០១២), *អវតារនិងកេតនកណ្ឌរបស់ព្រះវិស្ណុ* : ភ្នំពេញ។

ធន់ ហ៊ិន, (២០០៥), *រឿងរាមាយណៈ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ : ភ្នំពេញ។

ប៉ាង ខាត់, (១៩៦៨), *ប្រភពនាំឱ្យកើតមានសាសនាព្រាហ្មណ៍និងពុទ្ធសាសនា* : ការផ្សាយរបស់ពុទ្ធិកសិក្សា។

ពិ ប៊ុន្នីន(កត់ត្រា), (២០០០), *រាមកេរ្តិ៍ ពោលដោយតាសយ*, រោងពុម្ពពុទ្ធសាសនបណ្ឌិត្យ : ភ្នំពេញ។

ពុទ្ធសាសនបណ្ឌិត្យ, (១៩៩៥), *រាមកេរ្តិ៍១-១០ និងរាមកេរ្តិ៍៧៥-៨០*, បោះពុម្ពឡើងវិញលើកទី៤ : ភ្នំពេញ។

ពៅ សាវរស, (២០០៣), *កម្រងអត្ថបទវិជ្ជាខ្មែរ*, គ្រឹះស្ថានរៃយំ : ភ្នំពេញ។

មាស សុខ, (២០០៧), *មរតកក្បាច់គុន ល្បុក្កតោខ្មែរ* : ឧបត្ថម្ភបោះពុម្ពដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

មីសែល ត្រាណេ, (២០១២), *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ផ្ដើមពីវប្បធម៌ អារ្យធម៌នគរភ្នំ*, ផ្សាយដោយបណ្ណាគារសន្តិភាព : ភ្នំពេញ។

មីសែល ត្រាណេ និង ចាន់ សន, (២០០៤), *សង្ខេបរឿងរាមកេរ្តិ៍និងចម្លាក់ប្រាសាទបុរាណនៅប្រទេសថៃ* : រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

មៀច ប៊ុណ្ណ, (២០០៨), *កម្រងឯកសារស្ដីពីប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ ភាគ២-៣*, គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ : ភ្នំពេញ។

មៀច ប៊ុណ្ណ, (២០០៧), *កម្រងឯកសារស្ដីពីប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ ភាគ១*, បោះពុម្ពផ្សាយលើកទី៣ដោយគ្រឹះស្ថានអង្គរ : ភ្នំពេញ។

យសោធរ, (លេខ១៣ ធ្នូ២០១៣), (លេខ១២ ធ្នូ២០១៧), (លេខ៥ ធ្នូ២០០៩-ធ្នូ២០១០), (លេខ៤ ធ្នូ២០០៨-ធ្នូ២០០៩), *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, រក្សាសិទ្ធិ យសោធរ : ភ្នំពេញ។

លាង ហាប់អាន, *រឿងរាមកេរ្តិ៍ (រាមកេរ្តិ៍បែបខ្មែរ, រាមាយណៈបែបឥណ្ឌា)*។

សាគូ សាមុត, (២០០៧), *រឿងរាមកេរ្តិ៍*, បណ្ណាគារអង្គរ : ភ្នំពេញ។

សេង សោភា, (២០០១), *ប្រៀបធៀបរឿងរាមកេរ្តិ៍និងរឿងរ៉ាមគៀន* (សារណាបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា), សាកលវិទ្យាល័យភូមិន្ទភ្នំពេញ : ភ្នំពេញ។

អ៊ីវ ចុង, (២០១៨), *សាកល្បងសិក្សារឿងរាមកេរ្តិ៍*, គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ : ភ្នំពេញ។

អួង វន, (២០០១), *រចនាបថប្រាសាទបុរាណខ្មែរ ពីរចនាបថភ្នំដាដល់រចនាបថបាយ័ន*។

អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប, (២០០៧), *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ*, ផ្សាយដោយហនុមានទេសចរណ៍ : ភ្នំពេញ។